សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Économiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


តាក់តែងឡើងដោយ
និស្សិតឈ្មោះ **កែវ ពិសិដ្ឋ**
**ក.ទូច ចរិយា**

សាស្ត្រាចារ្យណែនាំ
លោក **ហោ សុភ័ណ្ឌ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# លិខិតថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **កែវ ពិសិដ្ឋ** និងកញ្ញា **ទូច ចរិយា** ក្នុងនាមយើងខ្ញុំទាំងពីរ ជានិស្សិតផ្នែកនីតិសាស្រ្តនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ថ្នាក់បរិញ្ញាបត្រជំនាន់ទី១៩ ក្នុងឆ្នាំសិក្សា ២០១៥-២០១៩ ។

**យើងខ្ញុំសូមគោរពលំអោនកាយវាចារចិត្ត សម្តែងនូវកតញ្ញូតាធម៍ដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះអ្នកមានគុណរួមមាន:**

**លោកឪពុក ឡាច គីម អ្នកម្តាយ ឃុត សាឃីម**

**លោកឪពុក ឃឹម ខុន អ្នកម្តាយ អ៊ា ហឿន**

ដែលលោកបានផ្តល់កំណើត ព្រមទាំងចិញ្ចឹមបីបាច់ថែរក្សារូបកូនតាំងពីតូចវ័យកុមាររហូតដល់កូនចំរើនវ័យមកដល់សព្វថ្ងៃនេះ ។ មិនតែប៉ុណ្ណោះលោកទាំងពីរបាន បង្រៀន អប់រំប្រៀនប្រដៅកូនដោយផ្តល់នូវដំបូន្មានល្អៗក្នុងជីវិតមកដល់ពេលនេះ រហូតដល់កូនទទួលបានជោគជ័យជាមួយនឹងលទ្ធផលជាទីគាប់ប្រសើរនាថ្នាក់ឧត្តមសិក្សានេះ។ សូមលោកទាំងពីរមេត្តាទទួលនូវការគោរព និង ការដឹងគុណពីកូនប្រុសរបស់លោកទាំងពីរ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រីដែលជាព្រឹទ្ធបុរស លោកគ្រូ អ្នកគ្រូដែលជាសាស្រ្តាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលលោកបានខិតខំបង្រៀន និងផ្តល់នូវចំណេះដឹងក្នុងការជួយតម្រង់ទិសដៅដល់រូបយើងខ្ញុំទាំងពីរ តាំងពីការសិក្សាថ្នាក់មូលដ្ឋានរហូតដល់បញ្ចប់បរិញ្ញាបត្រនេះ ប្រកបដោយក្រមសីលធម៍វិជ្ជាជីវៈ ។**

ជាពិសេសជូនចំពោះលោកសាស្រ្តាចារ្យ ហោ សុភ័ណ្ឌ ដែលលោកគ្រូបានបង្ហាត់បង្ហាញនូវគំនិតជាច្រើនក្នុងការស្រាវជ្រាវប្រធានបទមួយនេះ ដោយលោកគ្រូបានខិតខំចំណាពេលវេលាដ៏មានតម្លៃរបស់លោកគ្រូក្នុងការជួយជ្រោមជ្រែងការស្រាវជ្រាវមួយនេះតាំងពីដើមរហូតដល់ចប់។ សារណាមួយនេះចេញជារូបរាងទៅបានក៏អាស្រ័យដោយលោកសាស្រ្តាចារ្យជាអ្នកណែនាំ ។

លោក លោកស្រីដែលជាបណ្ណារក្ស និស្សិតរៀមច្បង និងមិត្តនិស្សិតទាំងអស់គ្នាដែលបានគាំទ្រនូវកម្លាំងចិត្ត ព្រមទាំងផ្តល់ជាគំនិតយោបល់ល្អៗ

ជំរុញឲ្យការស្រាវជ្រាវមានលក្ខណៈកាន់តែប្រសើរ ដើម្បីទុកជាឯកសាក្នុងការស្រាវជ្រាវ នឹងព្រមទាំងការស្វែងយល់ជាមួយចំណេះដឹងបន្ថែមដល់និស្សិតជំនាន់ក្រោយទៀត។

ជាចុងក្រោយយើងខ្ញុំ សូមគោរព ជូនពរ ចំពោះលោកអ្នកមានគុណដូចដែលបានរៀបរាប់ខាងលើ ឲ្យជួបប្រទះនូវពុទ្ធពរ ទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** និងសេចក្ដីសុខសប្បាយ ចូលកើតមានដល់លោកអ្នកមានគុណទាំងអស់កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

ក្នុងនាមយើងខ្ញុំ ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្ត ជំនាន់ទី ១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចក្នុងឆ្នាំសិក្សា២០១៥-២០១៩ ។ ក្នុងឱកាសដ៏មានតម្លៃដែលសាកលវិទ្យាល័យផ្តល់ឲ្យ យើងខ្ញុំទាំងពីរ បានសម្រេចចិត្តជ្រើសរើស និងរៀបចំស្រាវជ្រាវតាក់តែងនូវសារណាមួយក្រោមប្រធានបទ មូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ដែលវាចេញពីការខិតខំសិក្សាស្រាវជ្រាវនាពេលកន្លងមក។

ការស្រាវជ្រាវនូវនេះប្រធានបទនេះ ទៅលើមូលហេតុគ្រឹះ និងមូលហេតុផ្សេងៗទៀតដែលនាំអោយមិនទទួលខុសត្រូវព្រហ្មទណ្ឌ របស់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបានប្រព្រឹត្តនូវអំពើរំលោភបំពានណាដែលច្បាប់ចាត់ទុកថាជាអំពើដែលបង្កគ្រោះថ្នាក់ដល់សង្គម អសន្តិសុខ និងអន្តរាយដល់ទំនាក់ទំនាក់ក្នុងសង្គម ដែលកំពុងកើតមានឡើង។

ការស្រាវជ្រាវនេះជាលក្ខខណ្ឌយ៉ាងសំខាន់ ក្នុងការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ដែលទាមទារឲ្យនិស្សិតគោរពឲ្យបានខ្ជាប់ខ្ជួននូវលក្ខខណ្ឌទាំងនេះ ដើម្បីបញ្ចប់ការសិក្សាប្រកបដោយជោគជ័យ។ មួយវិញទៀត ដើម្បីឆ្លើយតបទៅនឹងទឹកចិត្តដ៏មានតម្លៃក្នុងការណែនាំ ចង្អុលបង្ហាញ និងចែករំលែកនូវចំណេះដឹងព្រមទាំងគំនិតយោបល់យើងខ្ញុំទាំងពីរដើម្បីបញ្ចប់ការស្រាវជ្រាវបានដោយជោគជ័យ។

ទន្ទឹមនឹងនេះ ប្រធានបទខាងលើនេះ មានលក្ខណៈស្របទៅនឹងកំណែទម្រង់ប្រព័ន្ធច្បាប់ និងប្រពន្ធ័យុត្តិធម៌របស់រាជរដ្ឋាភិបាល ដោយហេតុថា ក្រមព្រហ្មទណ្ឌថ្មីនៃព្រះរាជាណាចក្រកម្ពុជា ទើបតែត្រូវបានអនុវត្តពេញលេញកាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ដែលតម្រូវឲ្យអ្នកសិក្សាផ្នែកនីតិសាស្រ្ត ក៏ដូចជាពលរដ្ឋក្នុងសង្គមធ្វើការស្វែងយល់បន្ថែមអំពីសញ្ញាណគតិយុត្តថ្មីៗដែលមាននៅក្នុងនៅក្នុងក្រមព្រហ្មទណ្ឌនេះ។ សារណាមួយនេះត្រូវបានចាប់ផ្តើមស្រាវជ្រាវពីថ្ងៃទី០១ ខែមិនា ឆ្នាំ២០១៩ ដល់ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០១៩ ។ ក្នុងរយៈពេលនេះយើងខ្ញុំបានប្រើប្រាស់ពេលវេលាក្នុងការស្វែងរកឯកសារដែលពាក់ព័ន្ធនឹងប្រធានបទ និងការពិគ្រោះយោបល់ជាមួយលោកគ្រូសាស្រ្តាចារ្យដើម្បីធ្វើឲ្យការរៀបចំតាក់តែងសារណាមួយនេះ ដែលអាចយកជាការបានទៅតាមពេលដែលបានកំណត់ និងទៅតាមទំហំនៃប្រធានបទ។

ចុងបញ្ចប់ក្នុងនាមយើងខ្ញុំ ជាអ្នករៀបរៀងនូវសារណាមួយនេះមានគោលបំណង និងសង្ឃឹមថាស្នាដៃមួយនេះនឹងក្លាយជាប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវ និងជំនួយដល់ការពង្រីកចំណេះដឹងបន្ថែមដល់និស្សិតដែលកំពុងសិក្សាទៅតាមតម្រូវការរៀងៗខ្លួន។

# សេចក្តីផ្តើម

ច្បាប់ដែលត្រូវបានបង្កើតឡើង សុទ្ធតែមានបំណងស្វែងរកយុត្តិធម៌ជូនប្រជាជននៃប្រទេសមួយ។ ច្បាប់តឹង ធ្វើឲ្យប្រជាពលរដ្ឋមានសេចក្តីថ្លៃថ្នូរ ហើយប្រជាពលរដ្ឋនៃប្រទេសមានសេចក្តីថ្លៃថ្នូរបាន លុះត្រាតែពលរដ្ឋម្នាក់ៗនៃប្រទេសនោះ គោរពច្បាប់បានត្រឹមត្រូវផងដែរ។ ជាមួយគ្នានេះ ដើម្បីឲ្យប្រជាពលរដ្ឋគោរពច្បាប់ លុះត្រាតែស្ថាប័នតុលាការ គឺត្រូវតែជាស្ថាប័នដែលមានភាពយុត្តិធម៌ជាទីបំផុត។ បើសិនជាមានករណីជនដែលគ្មានកំហុស តែបែរជាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌនោះ វាក៏ជារឿងអយុត្តិធម៌ដែរ។ ដើម្បីធានាថា រាល់ការសម្រេចរបស់ស្ថាប័នតុលាការពិតជាប្រកបដោយភាពត្រឹមត្រូវនោះ លុះត្រាតែការសម្រេចសេចក្តីនោះត្រូវបានធ្វើឡើងតាមនីតិវិធីកំណត់ជាធរមាន។ អ្វីដែលយុត្តិធម៌នោះ គឺជនដែលមានកំហុសត្រូវតែទទួលទោសទណ្ឌពីអំណាចនៃច្បាប់ ពោលពីស្ថាប័នតុលាការដែលត្រូវបានគេស្គាល់ថា ជាស្ថាប័នការពារយុត្តិធម៌នេះ។ សម្រាប់ជនគ្មានកំហុសវិញ គឺគ្មានទោសទណ្ឌ ឬមិនត្រូវបានឲ្យទទួលខុសត្រូវព្រហ្មទណ្ឌអ្វីឡើយ។

ការរស់នៅក្នុងសង្គមសព្វថ្ងៃ បុគ្គលគ្រប់រូប គឺមានសិទ្ធិ និងសេរីភាពស្មើៗគ្នា ហើយវាត្រូវបានគ្រប់គ្រង និងកំណត់ដោយច្បាប់ ដើម្បីការពារនៅពេលដែលមានការប្រព្រឹត្តនូវបទល្មើសកើតឡើងដែលផ្ទុយនឹងច្បាប់បានបញ្ញត្តិ។ ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសនីតិរដ្ឋដែលគោរពច្បាប់ជាគោល និងជារដ្ឋមួយ ដែលគោរពតាមលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស ហើយនៅក្នុងនោះកម្ពុជាក៏បានបង្កើតច្បាប់ដើម្បីគ្រប់គ្រងនូវរាល់ទំនាក់ទំនងសង្គម ដូចជាក្រមព្រហ្មទណ្ឌជាដើម ដែលបង្កើតឡើងក្នុងគោលបំណងសម្រាប់កាពារដល់បុគ្គលគ្រប់រូប ទាំងអាយុជីវិត កិត្តិយស សេចក្តីថ្លៃថ្នូរ សិទ្ធិសេរីភាព និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ។ ក្នុងនោះក៏តែងតែកើតមានឡើងនូវការប្រព្រឹត្តបទល្មើសមួយចំនួន ដែលមិនស្របច្បាប់ និងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បូរណភាពរាងកាយ អាយុជីវិត

ព្រមទាំងទំនាក់ទំនងសង្គមផងដែរ ហើយក៏ជាបទល្មើសដែលចាត់ទុកជាអំពើល្មើសនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា។ ប៉ុន្តែបើបុគ្គលណាម្នាក់ បានប្រព្រឹត្តអំពើណាមួយ ដែលមិនមានចែងនៅក្នុងច្បាប់ បុគ្គលនោះនឹងមិនត្រូវបានទទួលទោសទណ្ឌពីរដ្ឋឡើយ។ ប៉ុន្តែផ្ទុយទៅវិញ បុគ្គលដែលប្រព្រឹត្តអំពើណាមួយ ដែលមានចែងក្នុងច្បាប់ បុគ្គលនោះត្រូវទទួលទោសទណ្ឌពីរដ្ឋ ដែលត្រូវបានគេហៅដោយជាក់លាក់ថា ការទទួលខុសត្រូវព្រហ្មទណ្ឌ។ ជាទូទៅ នីតិបុគ្គលត្រូវបានច្បាប់តម្រូវមិនឲ្យទទួលខុសត្រូវព្រហ្មទណ្ឌទេ ពោលមានតែរូបវន្តបុគ្គលប៉ុណ្ណោះដែលច្បាប់តម្រូវឲ្យទទួលខុសត្រូវព្រហ្មទណ្ឌ។ ទោះបីជាយ៉ាងណាក៏ដោយ មានករណីខ្លះការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដែលច្បាប់ចាត់ទុកថាត្រឹមត្រូវ ច្បាប់មិនតម្រូវឲ្យរូបវន្តបុគ្គលនោះ ទទួលខុសត្រូវព្រហ្មទណ្ឌដែរ។

ផ្អែកតាមប្រធានបទរបស់យើងខ្ញុំ ដែលសរសេរអំពីការមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ យើងខ្ញុំនឹងបកស្រាយពីមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ដែលជំពូកទី១ មូលហេតុដែលហៅថាអត្តនោម័ត ដោយឡែកជំពូកទី២ មូលហេតុដែលហៅថាសត្យានុម័ត ឬយុត្តិកម្មនៃបទល្មើស និងមួយវិញទៀត មូលហេតុផ្សេងទៀត ដែលយកមកបកស្រាយនៅជំពូកទី៣។

# ជំពូកទី១

# មូលហេតុដែលហៅថាអត្តនោម័ត

## ផ្នែកទី១ មូលហេតុអត្តនោម័តដោយសារភាពមានវិបល្លាសស្មារតី

វិបល្លាសស្មារតី សំដៅលើវិបត្តិដែលធ្វើឲ្យមានភាពរឹករវដល់សកម្មភាពនៃសរសៃប្រសាទរបស់មនុស្ស។ វិបល្លាសស្មារតីអាចមានប្រភពមកពីជរាភាពគ្រោះថ្នាក់ ឬមកពីជម្ងឺណាមួយជាដើម។ ដោយសារប្រព័ន្ធសរសៃប្រសាទមានសកម្មភាពមិនប្រក្រតី ចារីបានបាត់បង់នូវលទ្ធភាពយល់ដឹងពីពិភពខាងក្រៅជុំវិញខ្លួន ហើយពុំអាចត្រួតពិនិត្យសកម្មភាពរបស់ខ្លួនបានទេ[1]។

មាត្រា ៣១ នៃក្រមព្រហ្មទណ្ឌកម្ពុជា ២០០៩ កថាខណ្ឌទី១ ចែងថា កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតីដែលធ្វើឱ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ[2]។

ជាការកត់សម្គាល់ នៅក្នុងការសិក្សាមុខវិជ្ជានីតិព្រហ្មទណ្ឌ គេមិនឃើញមានការកំណត់ច្បាស់ពីប្រភេទនៃមនុស្សវិកលចរិតឡើយ។ ទោះជាយ៉ាងនេះក្តី គេឃើញនៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជា កំណត់ថា ជនវិបល្លាសស្មារតី

[1] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត(ភ្នំពេញ៖ ២០១២), ២៣៨។

[2] ក្រមព្រហ្មទណ្ឌកម្ពុជា, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣១, កថាខណ្ឌទី១។

ត្រូវបានចែកចេញជាពីរគឺ ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ។ ជននៅក្រោមអាណាព្យាបាលទូទៅ មានន័យថា ជនស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី[3]។ ជាមួយគ្នានេះ ជននៅក្រោមហិតូបត្ថម្ភ មានន័យថា ជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី[4]។

## ១.១. ជនវិប្លាសស្មារតីទាំងស្រុងនូវការយល់ដឹង

ដូចដែលបានបកស្រាយខាងលើម្ដងហើយថា មាត្រា ៣១ កថាខណ្ឌទី១ កំណត់ថា កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលធ្វើឲ្យខាតបង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌ។ ផ្អែកតាមស្មារតីនៃមាត្រានេះ ជនវិបល្លាសស្មារតី រួចផុតពីការទទួលខុសត្រូវទាំងស្រុង។

ដើម្បីឲ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ គេត្រូវតែរកភស្តុតាងមកបញ្ជាក់ពីអត្ថិភាពនៃវិបល្លាសស្មារតីដែលចារីមាន នៅពេលប្រព្រឹត្តបទល្មើស។ ភស្តុតាងនេះត្រូវតែរកឲ្យបាន ពោលគឺ មានការសន្មត់ថាជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅក៏ដោយ។ ជាទូទៅភស្តុតាងនៃវិបល្លាសស្មារតីត្រូវបញ្ជាក់ដោយវេជ្ជបណ្ឌិតជំនាញ ក៏ប៉ុន្តែយោបល់ទាំងនោះពុំមានអានុភាពចងជាកាតព្វកិច្ចឲ្យចៅក្រមត្រូវតែជឿតាមទេ ពោលគឺចៅក្រមអាចជឿក៏បាន មិនជឿក៏បានដែរ[5]។

នៅក្នុងច្បាប់ហៅថា វិបល្លាសស្មារតី គឺសំដៅទៅលើអ្នកដែលមានសតិបញ្ញាស្មារតីមិនប្រក្រតី ហើយគេអាចហៅថាជាជនវិកលចរិត ឬក៏ហៅថាមនុស្សឆ្កួតស៊ប់[6]។

---

[3] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ២៥។

[4] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ២៨។

[5] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៣៩។

[6] កៅ សីហា, *នីតិព្រហ្មទណ្ឌទូទៅ* (ភ្នំពេញ៖ អង្គរ, ២០១៣), ២៣៧។

ដូច្នេះស្ថានភាពស្មារតីនេះ បើសិនជាគាត់ស្ថិតក្រោមរបបអាណាព្យាបាលទូទៅ បានន័យថា ជាមនុស្សវិកលចរិត ឬជាមនុស្សឆ្កួតស៊ប់ ដែលបាត់បង់នូវការដឹងខុសត្រូវទាំងស្រុង ឬក៏ជានិរន្តរ៍នោះបានទៅប្រព្រឹត្តបទល្មើស មនុស្សប្រភេទនេះនឹងរួចផុតពីការទទួលខុសត្រូវ[7]។

**ឧទាហរណ៍:** មានបុរស «ក» ម្នាក់ត្រូវបានជនវិកលចរិតយកកាំបិតចាក់យ៉ាងពេញទំហឹងបណ្តាលឲ្យស្លាប់ភ្លាមៗ។ ករណីនេះ ជនវិកលចរិតនោះ នឹងមិនត្រូវបានផ្តន្ទាទោសពីច្បាប់ព្រហ្មទណ្ឌឡើយ បើសិនជាមានភស្តុតាងបញ្ជាក់ថាគាត់ពិតជាគ្មានសមត្ថភាពដឹងខុសត្រូវពិតប្រាកដមែន។

### ១.២. ជនវិប្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវ

វិបល្លាសស្មារតី ដែលជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវតែជាវិបល្លាសដែលបានបំផ្លាញចោលទាំងស្រុងនូវសមត្ថភាពក្នុងការយល់ដឹងរបស់ចារី (លទ្ធភាពក្នុងការយល់ន័យនៃអំពើរបស់ខ្លួន ឬការយល់ដឹងខុសត្រូវក្នុងការប្រព្រឹត្តអំពើ) ឬបំផ្លាញចោលទាំងស្រុងនូវសមត្ថភាពក្នុងការត្រួតពិនិត្យសកម្មភាពរបស់ខ្លួន។ ប្រសិនបើចារីមានវិបល្លាសស្មារតី ដែលត្រឹមតែបន្ថយនូវការដឹងខុសត្រូវរបស់គាត់តែប៉ុណ្ណោះ គាត់នៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ក៏ប៉ុន្តែស្ថានភាពនេះ អាចក្លាយជាស្ថានភាពសម្រាលទោសសម្រាប់ចារីបាន[8]។

លើសពីនេះទៅទៀត បើគេយោងតាមសៀវភៅនីតិព្រហ្មទណ្ឌទូទៅ របស់លោក កៅ សីហា ផ្តល់គំនិតបន្ថែមថា ប្រសិនបើក្នុងករណីដែលជនវិបល្លាសស្មារតីណាម្នាក់ប្រព្រឹត្តបទល្មើស ដោយបាត់បង់នូវការទទួលខុសត្រូវត្រឹមតែមួយផ្នែក គឺគាត់នៅតែទទួលខុសត្រូវព្រហ្មទណ្ឌ។ ប៉ុន្តែនៅពេលដែលតុលាការដាក់ទោស គេនឹងពិនិត្យអំពីស្ថានភាព ដែលគាត់បានប្រព្រឹត្តបទល្មើសនោះ

[7] កៅ សីហា, *នីតិព្រហ្មទណ្ឌទូទៅ* (ភ្នំពេញៈ អង្គរ, ២០១៣), ២៣៧។

[8] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញៈ ២០១២), ២៣៩។

ហើយដោយសារតែគាត់បាត់បង់នូវការយល់ដឹងទាំងស្រុងទេ គឺគ្រាន់តែបន្ថយនូវការយល់ដឹងតែប៉ុណ្ណោះ ដូច្នេះគាត់នៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល[9]។

ជាក់ស្ដែង នៅក្នុងមាត្រា៣១ នៃក្រមព្រហ្មទណ្ឌកម្ពុជា កថាខណ្ឌទី២ ចែងថា កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតមានវិបល្លាសស្មារតី ដែលបន្ថយនូវការយល់ដឹងរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។ ប៉ុន្តែតុលាការត្រូវគិតគូរបញ្ហានេះ កាលណាតុលាការកំណត់ទោស[10]។ ផ្អែកតាមស្មារតីមាត្រានេះ បុគ្គលបានប្រព្រឹត្តបទល្មើស ស្របពេលដែលបុគ្គលនោះស្ថិតនៅក្នុងស្ថានភាពដូចខាងលើ គេមិនរួចពីការទទួលខុសត្រូវនោះទេ តែអាចទទួលបានការសម្រាលពីច្បាប់។

បើយោងតាមសៀវភៅមេរៀននីតិព្រហ្មទណ្ឌខ្មែរ ដែលត្រូវបានរៀបចំឡើងដោយសហប្រតិបត្តិការបារាំងគាំពារទ្រទ្រង់នីតិរដ្ឋ បញ្ជាក់ថា មាត្រា៣១ កថាខណ្ឌ២ នៃក្រមព្រហ្មទណ្ឌកម្ពុជា សំដៅលើជនម្នាក់កើតវិបល្លាសស្មារតី នៅពេលឆ្លងទៅរកសកម្មភាព ប៉ុន្តែកម្លាំងនៃវិបល្លាសនេះ ពុំមានលក្ខណៈលុបបំបាត់ទាំងស្រុងនូវសមត្ថភាពដឹងខុសត្រូវទេ ពោលកម្លាំងនៃវិបល្លាសនេះ គ្រាន់តែត្រូវបានកាត់បន្ថយតែប៉ុណ្ណោះ[11]។ ដូច្នេះករណីនេះ លែងជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ប៉ុន្តែជាមូលហេតុនៃការបន្ថយការទទួលខុសត្រូវព្រហ្មទណ្ឌ ពីព្រោះថាបុគ្គលនោះត្រូវបានជំនុំជម្រះដោយតុលាការ ត្រូវតែលើកយកមកពិចារណានូវស្ថានភាពនេះដើម្បីកំណត់ទោស។

នៅក្នុងការអនុវត្តជាក់ស្ដែង ការដឹងខុសត្រូវចុះថយនេះ អនុញ្ញាតឲ្យបន្ថយទោសបាន។ ទស្សនៈនៃបទបញ្ញត្តិនេះ គឺច្បាស់លាស់ណាស់ បទល្មើសតម្រូវឲ្យមានចេតនាធ្វើសកម្មភាព

[9] កៅ សីហា, *នីតិព្រហ្មទណ្ឌទូទៅ* (ភ្នំពេញ៖ អង្គរ, ២០១៣), ២៣៨។

[10] ក្រមព្រហ្មទណ្ឌកម្ពុជា, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣១, កថាខណ្ឌទី២។

[11] សហប្រតិបត្តិការបារាំងគាំពារទ្រទ្រង់នីតិរដ្ឋ, *មេរៀននីតិព្រហ្មទណ្ឌខ្មែរ* (២០០៨), ៥០។

ហើយថែមទាំងភាពដែលអាចទម្លាក់កំហុសបាន មានន័យថា លទ្ធភាពដែលអាចត្រូវបានគេស្តីបន្ទោស។ ប៉ុន្តែជនណាដែលមានវិកលចរិតអាចមានបំណងប្រព្រឹត្តបទល្មើស ដោយពុំមានលទ្ធភាពវាស់វែងឲ្យបានពិតប្រាកដនូវផលវិបាក នៃសកម្មភាពដែលខ្លួននឹងប្រព្រឹត្ត ជននោះពុំមានស្មារីតពិតប្រាកដទេ។ ប្រសិនបើពុំមានភាពដែលពុំអាចទម្លាក់កំហុសបាននោះទេ ជាធម្មតាទេដែលការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ត្រូវបានច្រានចេញ[12]។

### ១.៣. ជនដែលមានវិល្លាសស្មារតីដោយសារការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន

បើយោងតាមមាត្រា៣១ ក្រមព្រហ្មទណ្ឌកម្ពុជា កថាខណ្ឌទី៣ ចែងថា កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ[13]។ ផ្អែកតាមស្មារតីនៃមាត្រានេះ បុគ្គលម្នាក់ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ស្របពេលដែលខ្លួនស្ថិតក្រោមឥទ្ធិពលនៃគ្រឿងញៀន ឬគ្រឿងស្រវឹង គេមិនអាចចាត់ទុកថាបុគ្គលនោះ មានវិបល្លាសស្មារតីឡើយ ពោលជននោះត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌជាធរមាន។

វិបល្លាសស្មារតីដែលកើតចេញពីការប្រើប្រាស់គ្រឿងញៀន គ្រឿងស្រវឹង និងថ្នាំដែលច្បាប់ហាមឃាត់ច្រើនតែកើតចេញពីឆន្ទៈផ្ទាល់របស់ចារីតែម្តង ហើយក៏មិនអាចចាត់ទុកថាជាមូលហេតុដែលនាំអោយមានការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដែរ។ **ឧទាហរណ៍:** បុរសម្នាក់បានប្រើប្រាស់ថ្នាំញៀន ឬផឹកគ្រឿងស្រវឹង បណ្តាលឱ្យបាត់បង់ការគ្រប់គ្រងលើខ្លួនឯង ហើយក៏បានទៅវាយបុរសម្នាក់ទៀតដែលនៅក្បែរនោះបណ្តាលអោយរងរបួសធ្ងន់ ។ ជនល្មើសនោះមិនអាចប្រើប្រាស់ ឬលើកយកនូវមូលហេតុដែលខ្លួនស្រវឹង

[12] សហប្រតិបត្តិការបារាំងគាំពារទ្រទ្រង់នីតិរដ្ឋ, *មេរៀននីតិព្រហ្មទណ្ឌខ្មែរ* (២០០៨), ៥១។

[13] ក្រមព្រហ្មទណ្ឌកម្ពុជា, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣១, កថាខណ្ឌទី៣។

យកមកធ្វើជាហេតុផលមួយដែលអាចធ្វើឲ្យខ្លួនមានការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ ដោយឡែកបុរសដែលប្រព្រឹត្តនោះនឹងត្រូវតែប្រឈមមុខនូវរាល់កំហុសទាំងអស់ដែលខ្លួនបានប្រព្រឹត្ត ពីព្រោះថាមូលហេតុដែលខ្លួនប្រុងនឹងលើកយកមកអះអាងនៅ ទីនេះមិនមានច្បាប់ណាមួយបញ្ជាក់ថាអាចយកមកធ្វើជាភស្តុតាងផ្ទុយបាននោះទេ ។[14]

លើសពីនេះទៅទៀត សៀវភៅរបស់លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ បង្ហាញដែរថា បញ្ហាចោទឡើងចំពោះការប្រើប្រាស់ថ្នាំផ្សេងៗ ដែលមានឥទ្ធិពលប៉ះពាល់ដល់ប្រព័ន្ធប្រសាទដូចជា គ្រឿងញៀន សុរា ឬថ្នាំផ្សេងៗទៀតជាដើម។ ការប្រើប្រាស់ថ្នាំទាំងអស់នោះច្រើនពេកអាចធ្វើឲ្យខូចខាតដល់ប្រព័ន្ធសរសៃប្រសាទគ្រប់គ្រងខ្លួនមនុស្សមួយរយៈពេលបាន។ ប៉ុន្តែការកំណត់ថាការប្រើប្រាស់គ្រឿងបំពុលនេះជាមូលហេតុនៃការមិនទទួលខុសត្រូវបានបង្កជាចំណោទមួយដ៏លំបាកស្មុគស្មាញពីព្រោះថា ការប្រើប្រាស់គ្រឿងបំពុលច្រើនតែកើតចេញពីឆន្ទៈរបស់អ្នកប្រើប្រាស់តែម្តង។ ហេតុដូច្នេះហើយ ទើបក្រមព្រហ្មទណ្ឌត្រង់មាត្រា ៣១ កថាខណ្ឌទី៣ មិនចាត់ទុកថាវិបល្លាសស្មារតីដែលបានកើតចេញពីការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់ ជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ[15]។

សៀវភៅរបស់លោក កៅ សីហា អះអាងផងដែរថា ច្បាប់បានកំណត់ដើម្បីឲ្យទទួលខុសត្រូវផងដែរចំពោះអ្នកប្រើប្រាស់សារជាតិដែលច្បាប់ហាមឃាត់ ឬគ្រឿងញៀន ឬមួយផឹកស្រាស្រវឹងក៏ទៅប្រព្រឹត្តបទល្មើស ដោយយកលេសថាមានវិបល្លាសស្មារតី ដើម្បីរួចផុតពីការទទួលខុសត្រូវនោះ ច្បាប់មិនទទួលស្គាល់ទង្វើបែបនេះឡើយ[16]។

---

[14] សារណាបញ្ចប់ការសិក្សារបស់ លោក សុធា រស្មី និងលោក អៀង វណ្ណៈ (ឆ្នាំ២០១៦)។

[15] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៨០។

[16] កៅ សីហា, *នីតិព្រហ្មទណ្ឌទូទៅ* (ភ្នំពេញ៖ អង្គរ, ២០១៣), ២៣៨។

**ឧទាហរណ៍:** បុរសម្នាក់ដែលជាអ្នកចូលចិត្តដើរលេងយប់ បានប្រើប្រាស់ថ្នាំញៀន ដើម្បីភាពសប្បាយរីករាយ។ ភ្លាមៗនោះ ដោយសារតែឥទ្ធិពលនៃថ្នាំញៀន បានធ្វើឱ្យបុរសម្នាក់នោះទៅចាប់រំលោភសេពសន្ថវៈលើស្ត្រីម្នាក់។ ជាលទ្ធផលបុរសម្នាក់នោះ មិនអាចលើកហេតុផលថា មូលហេតុនៃការប្រព្រឹត្តបទល្មើសរបស់ខ្លួន បណ្តាលមកពីឥទ្ធិពលគ្រឿងញៀនឡើយ ពោលបុរសម្នាក់នោះ ត្រូវតែទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដដែល។

**ផ្នែកទី២ មូលហេតុអត្តនោម័តដោយសារអានុភាពនៃកម្លាំង ឬការបង្ខំ**

មាត្រា៣៦ នៃក្រមព្រហ្មទណ្ឌកម្ពុជា ចែងថា បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬនៃការបង្ខំ ដែលបុគ្គលនេះមិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ។ កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ។ កម្លាំងនេះ ត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចចៀសបាន[17]។

ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ មិនបានឲ្យនិយមន័យលើពាក្យ អានុភាពនៃកម្លាំង និងការបង្ខំ ឡើយ។ ចំណែកឯក្រមព្រហ្មទណ្ឌចាស់កម្ពុជា១៩៦៧វិញ ក៏មិនបានប្រើពាក្យ អានុភាពនៃកម្លាំង ឬការបង្ខំទេ ប៉ុន្តែបានអោយនិយមន័យ នៃពាក្យនេះនៅមាត្រា៩៦ យ៉ាងដូច្នេះថា កាលបើមានភស្តុតាងថា មានកម្លាំងអ្វីមួយបានបង្ខំជនណាម្នាក់ឲ្យប្រព្រឹត្តបទល្មើសអ្វីមួយ ហើយជននោះកាលមិនអាចទប់ទល់នឹងកម្លាំងនោះបានទេ ក៏ប្រព្រឹត្តិបទល្មើសនោះទៅ។ ជនប្រព្រឹត្តបទល្មើសនេះមិនត្រូវឲ្យទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្តឡើយ[18]
។

មាត្រា៩៧ នៃក្រមព្រហ្មទណ្ឌចាស់កម្ពុជាឆ្នាំ១៩៦៧ដដែល ឲ្យនិយមន័យនៃពាក្យ កម្លាំងបង្ខំ ថាជាគ្រោះថ្នាក់ណាមួយដែលបណ្តាលឲ្យមានអាសន្នយ៉ាងធំបំផុត[19]។ ពាក្យថាអាសន្នយ៉ាងធំបំផុត មានន័យថាគ្រោះថ្នាក់មួយយ៉ាងធំបំផុត

---

[17] ក្រមព្រហ្មទណ្ឌកម្ពុជា, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៦។

[18] ក្រមព្រហ្មទណ្ឌចាស់កម្ពុជាឆ្នាំ១៩៦៧, មាត្រា៩៦ ។

[19] ក្រមព្រហ្មទណ្ឌចាស់កម្ពុជាឆ្នាំ១៩៦៧, មាត្រា៩៧ ។

ដែលនឹងត្រូវធ្លាក់មកលើខ្លួន ក្នុងពេលជាបន្ទាន់ក្រៃពេកមិនអាចឲ្យខ្លួនចៀសផុតពីគ្រោះនេះបាន ដោយមិនបានប្រព្រឹត្តបទល្មើសមួយនោះទេ ម្យ៉ាងទៀតគ្រោះថ្នាក់នោះ កាលបើកើតឡើងក៏មិនមែនកើតឡើងពីឆន្ទៈផ្ទាល់របស់ចារីនៃបទល្មើសនោះដែរ នឹងមិនមែនចារីនោះជាអ្នកបង្កើត ឬជាអ្នកបណ្ដាលឲ្យមានគ្រោះថ្នាក់នោះដែរ[20]។

មាត្រា៩៩ នៃក្រមព្រហ្មទណ្ឌចាស់ ជានិយមន័យដ៏សំខាន់ក្នុងការឈានទៅដល់កាស្វែងយល់ពីនិយមន័យពីមាត្រា ៣៦ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌចាស់នៃព្រះរាជាណាចក្រកម្ពុជា ពីព្រោះមាត្រាទាំងពីរនេះមានខ្លឹមសារប្រហាក់ប្រហែលគ្នា។ដូចនេះតាមរយៈខ្លឹមសារនៃមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌចាស់(១៩៦៧) យើងអាចសន្មត់បាននូវនិយមន័យនៃពាក្យថា **អានុភាពនៃកម្លាំងបង្ខំ ឬការបង្ខំ** គឺសំដៅដល់គ្រោះថ្នាក់យ៉ាងធំបំផុតនឹងត្រូវធ្លាក់មកលើជនណាម្នាក់ក្នុងពេលជាបន្ទាន់ដោយមិនអាចនឹងជៀសវាងបាន លុះត្រាតែចារីបានប្រព្រឹត្តបទល្មើសហើយបទល្មើសនោះទៀតសោតក៏មិនបានចេញពីឆន្ទៈរបស់ចារីដែរ។[21]

កម្លាំង ឬការបង្ខំ អាចកើតចេញតែពីហេតុការណ៍ខាងក្រៅឆន្ទៈរបស់មនុស្សប៉ុណ្ណោះ ការបង្ខំ ឬកម្លាំងនេះ ត្រូវតែមិនអាចប៉ាន់ស្មានទុកជាមុន និងមិនអាចទប់ទល់បាន[22]។

ការបង្ខំបង្កើតបានជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ដោយហេតុថាការបង្ខំនេះលុបចោលនូវឆន្ទៈ ពីព្រោះថាចារីត្រូវស្ថិតនៅក្នុងស្ថានភាពមួយដែលពុំមានជម្រើសផ្សេងក្រៅពីប្រព្រឹត្តនូវអ្វីដែលខ្លួនបានប្រព្រឹត្ត[23]។ តាមការពិតការបង្ខំនេះ បង្កើតបានជាករណីប្រធានសក្តិមួយសម្រាប់ចារីក្នុងការទទួលបាននូវសេរីភាព។

---

[20] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ,* កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៤២។

[21] សារណាបញ្ចប់ការសិក្សារបស់ លោក សុធា រស្មី និងលោក អៀង វណ្ណៈ (ឆ្នាំ២០១៦)។

[22] សហប្រតិបត្តិការបារាំងគាំទ្រនីតិរដ្ឋ, *មេរៀននីតិព្រហ្មទណ្ឌទូទៅខ្មែរ* (២០០៨), ៤១។

[23] សហប្រតិបត្តិការបារាំងគាំទ្រនីតិរដ្ឋ, *មេរៀននីតិព្រហ្មទណ្ឌទូទៅខ្មែរ* (២០០៨), ៤០។

ជាទូទៅគេចាត់ទុកថា កម្លាំង ឬការបង្ខំ អាចមានពីរប្រភេទ (២.១) និងការបង្ខំលើផ្លូវចិត្ត (២.២) ដើម្បីឲ្យក្លាយជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ។

**២.១. ប្រភេទនៃកម្លាំង ឬការបង្ខំ**

កម្លាំង ឬការបង្ខំមានពីរប្រភេទ គឺការបង្ខំលើរូបរាងកាយ (២.១.១) និង ការបង្ខំលើផ្លូវចិត្ត (២.១.២)

**២.១.១. កម្លាំងបង្ខំលើរូបកាយ**

ការបង្ខំលើរូបកាយ សំដៅទៅលើវត្តមាននៃកម្លាំងណាមួយលើរូបកាយរបស់ចារី ដែលជាមូលហេតុធ្វើឲ្យចារីត្រូវតែប្រព្រឹត្តអំពើ ដោយខ្លួនពុំអាចឃាត់ឃាំងអំពើនោះបាន[24]។ ការបង្ខំលើរូបកាយអាចនៅខាងក្នុង ឬនៅខាងក្រៅ។

កម្លាំងបង្ខំអាចជាកម្លាំងបង្ខំមកពីខាងក្រៅ ដូចជា កម្លាំងបង្ខំមកពីព្រឹត្តិការណ៍ធម្មជាតិ មកពីសត្វ ឬមកពីតតិយជនណាមួយ។ ឧទាហរណ៍: កំពុងតែធ្វើដំណើរលើផ្លូវ ស្រាប់តែមានខ្យល់ព្យុះ បណ្តាលឲ្យបុរសម្នាក់មិនអាចគ្រប់គ្រងចង្កូតរថយន្តបាន ក៏ឈានដល់បុកអ្នកដំណើរម្នាក់ស្លាប់ភ្លាម។ ជនបង្កមិនត្រូវដាក់ដាក់ទោសបានឡើយ ដោយសារមូលហេតុនៃអំពើគ្រោះថ្នាក់ មិនបានកើតពីឆន្ទៈខ្លួន ពោលការដែលបណ្តាលឲ្យរថយន្តជ្រុលចង្កូតទៅបុកអ្នកដទៃ វាកើតឡើងពីកម្លាំងធម្មជាតិ។

ក្រៅពីនេះ កម្លាំងបង្ខំអាចជាកម្លាំងបង្ខំមកពីស្ថានភាពខាងក្នុងផ្ទាល់របស់ចារី។ ឧទាហរណ៍: នៅពេលកំពុងបើកបរធម្មតាលើដងផ្លូវ អ្នកបើកបរម្នាក់ស្រាប់តែរកកលវិលមុខ ធ្វើឲ្យស្មារតីមិនអាចគ្រប់គ្រងរថយន្តរបស់ខ្លួនបាន

[24] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៤៣។

បណ្តាលឲ្យបុកអ្នកដំណើរម្នាក់រងរបួស។ ករណីនេះហៅថា កម្លាំងបង្ខំមកពីស្ថានភាពខាងក្នុងផ្ទាល់របស់ចារី ដែលចារីនោះមិនត្រូវផ្តន្ទាទោសព្រហ្មទណ្ឌឡើយ។

គួរគូសបញ្ជាក់ថា មាត្រា៣៦ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌកម្ពុជា ចែងបញ្ជាក់ថា: កម្លាំង និងការបង្ខំអាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សប៉ុណ្ណោះ។ ចំណែកឯការបង្ខំលើរូបកាយដែលកើតចេញពីស្ថានភាពខាងក្នុងផ្ទាល់របស់ចារី គឺជាព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្ស តែជាស្ថានភាពដែលកើតចេញពីខ្លួនចារីផ្ទាល់។ ហេតុដូចនេះ គេមិនអាចឲ្យសន្និដ្ឋានបានថា ជំងឺរបស់ចារី គឺជាព្រឹត្តិការណ៍កើតចេញពីឆន្ទៈរបស់ចារីនោះទេ[25]។

### ២.១.២ ការបង្ខំលើផ្លូវចិត្ត

ការបង្ខំលើផ្លូវចិត្តសំដៅទៅលើកម្លាំងដែលបង្ខំឆន្ទៈរបស់ចារី[26]។ ការបង្ខំផ្លូវចិត្តក៏អាចជាមូលហេតុនៃការមិនទទួលត្រូវព្រហ្មទណ្ឌបានដែរ តែក្នុងករណីដែលការបង្ខំនោះមាន ប្រភពមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់ចារី ប៉ុណ្ណោះពោលគឺជាការគាបសង្កត់ខាងក្រៅ ដែលជំរុញឲ្យចារីមិនអាចបញ្ចៀសបានពីការប្រព្រឹត្តិបទល្មើស[27]។

ការបង្ខំខាងផ្លូវចិត្តនេះអាចលើកលែងចារីនៅពេល ដែលការបង្ខំនេះមានប្រភពមកពីខាងក្រៅ។ដូច្នេះនៅក្នុងករណីដែលចារីបានប្រព្រឹត្តដោយមានការគំរាមកំហែងដ៏ច្បាស់លាស់ ប្រឆាំងនឹងខ្លួនរបស់ចារី ឬប្រឆាំងនឹងតតិយជន ជននោះអាចមិនទទួលខុសត្រូវព្រហ្មទណ្ឌ[28]។ ដើម្បីឲ្យមានការគំរាមកំហែងក្លាយជាមូលហេតុនាំឲ្យចារីរួចផុតពីការទទួលខុសត្រូវព្រហ្មទ

---

[25] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៤៤។

[26] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៤៥។

[27] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៤៥។

[28] សហប្រតិបត្តិការបារាំងគាំពារទ្រទ្រង់នីតិរដ្ឋ, *មេរៀននីតិព្រហ្មទណ្ឌខ្មែរ* (២០០៨), ទំព័រ៤២។

ណ្ឌ ត្រូវតែមានភស្តុតាងបញ្ជាក់ថា ការគំរាមកំហែងពិតជាមានលក្ខណៈខុសច្បាប់[29]។ ឧទាហរណ៍: ចោរមួយក្រុមដឹងថា បុរសម្នាក់បានដឹកជញ្ជូនប្រាក់យ៉ាងច្រើនពីធនាគារជាតិទៅប្រើប្រាស់តាមការចាត់ចែងរបស់មន្ត្រីធនាគារជាតិ។ លុះធ្វើដំណើរដល់ពាក់កណ្ដាលផ្លូវ បុរសនោះត្រូវបានគំរាមកំហែងប្លន់យកប្រាក់ ដោយក្រុមចោរបញ្ជាឲ្យបើករថយន្តទៅកាន់ទីកន្លែងចោរ។ ករណីនេះ អ្នកដឹកជញ្ជូនពុំទទួលខុសត្រូវពីបទព្រហ្មទណ្ឌ ចំពោះអំពើនៃការប្លន់ប្រាក់នេះឡើយ ពីព្រោះថាខ្លួនបានប្រគល់ប្រាក់ទាំងនោះ ក្រោមការគំរាមកំហែងរបស់ តតិយជន ដែលជាក្រុមចោរ។

ផ្ទុយទៅវិញ ចំពោះការបង្ខំខាងផ្លូវចិត្តខាងក្នុង ការមិនទទួលខុសត្រូវព្រហ្មទណ្ឌអាចពុំត្រូវបានគេទទួលស្គាល់ទេ[30]។ ជាញឹកញាប់បំផុត ការបង្ខំខាងផ្លូវចិត្តនេះទាក់ទងនឹងសភាពជំងឺផ្នែកតណ្ហា ដែលកំណត់ការប្រព្រឹត្តរបស់ចារីដូចគ្នាដែរ ចំពោះតណ្ហា កំហឹង ភាពស្អប់ខ្ពើម។ ការបង្ខំខាងផ្លូវចិត្តខាងក្នុងនេះពុំមែនជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ លើកលែងករណីជ្រុល ឬសភាពជំងឺ ដែលឈានទៅរកការបាត់បង់នូវការដឹងខុសត្រូវ ដោយសារតែស្មារតីវិបល្លាស។ ជាក់ស្ដែងការបង្ខំលើផ្លូវចិត្តដែលមានប្រភពមកពីចារីផ្ទាល់ មិនអាចជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌបានទេ[31]។

**ឧទាហរណ៍:** ដោយសារការខឹង ការស្អប់ខ្ពើម ជំនឿផ្នែកមនោគមវិជ្ជា ឬសាសនាណាមួយ បានបង្ខំឲ្យចារីត្រូវតែប្រព្រឹត្តបទល្មើស។ ក្នុងករណីបែបនេះ ចារីនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ពីព្រោះថាការបង្ខំផ្លូវចិត្តនេះមានប្រភពមកពីព្រឹត្តិការណ៍ក្នុងឆន្ទៈរបស់ចារីផ្ទាល់តែម្ដង[32]។

### ២.២. លក្ខណៈនៃកម្លាំង ឬការបង្ខំ

[29] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៤៥។

[30] សហប្រតិបត្តិការបារាំងគំពងទ្រទ្រង់នីតិរដ្ឋ, *មេរៀននីតិព្រហ្មទណ្ឌខ្មែរ* (២០០៨), ទំព័រ៤២។

[31] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៤៥។

[32] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៤៦។

ក្នុងលក្ខណៈប្រហាក់ប្រហែលទៅនឹងករណីប្រធានសក្តិនៅក្នុងរឿងក្តីរដ្ឋប្បវេណីដែរ មាត្រា ៣៦ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌកម្ពុជា តម្រូវឲ្យកម្លាំង និងការបង្ខំមានលក្ខណៈពីរយ៉ាង ដើម្បីឲ្យកម្លាំង ឬការបង្ខំនេះក្លាយជាមូលហេតុនៃការមិនអាចទទួលខុសត្រូវព្រហ្មទណ្ឌបាន ពោលគឺកម្លាំង និងការបង្ខំត្រូវតែមិនអាចមើលឃើញជាមុនបាន (២.២.១) និងមិនអាចចៀសវាងបាន (២.២.២)[33]។

**២.២.១ កម្លាំង និង ការបង្ខំដែលមិនអាចមើលឃើញជាមុនបាន**

កម្លាំង និងការបង្ខំត្រូវតែជាស្ថានភាពដែលមិនអាចមើលឃើញជាមុនបាន ពោលគឺជនប្រព្រឹត្តបទល្មើសមិនអាចប៉ាន់ស្មានដឹងជាមុនបានឡើយ ហើយក៏ពុំមែនកើតចេញពីកំហុសណាមួយផ្ទាល់របស់គាត់ផ្ទាល់ដែរ។ ក្នុងន័យនេះជនដែលខ្វះការប្រុងប្រយ័ត្នក្នុងការទប់ស្កាត់អំពើដែលអាចបង្ខំអោយខ្លួនឯងប្រព្រឹត្តបទល្មើស មិនលើកសំអាងពីកម្លាំង ឬការបង្ខំ ដើម្បីឲ្យខ្លួនរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនោះឡើយ[34]។ **ឧទាហរណ៍:** អ្នកបើកបរមិនអាចលើកសំអាងថា ខ្លួនមិនអាចដឹងជាមុនថាម៉ាស៊ីនឡានរបស់ខ្លួនខូចបណ្តាលឲ្យគាត់បើកបរបង្ករបួសដល់ជនរងគ្រោះឡើយ ពីព្រោះថាគាត់បានធ្វេសប្រហែសមិនបានមើលថែទាំរថយន្តរបស់គាត់ឲ្យបានល្អ[35]។ ជាមួយគ្នានេះ អ្នកបើកបរមិនអាចលើកសំអាងថា ដោយសារការបើកបររថយន្តរយៈពេលវែង និងមិនបានបរិភោគអាហារគ្រប់គ្រាន់ ធ្វើឲ្យសុខភាពផ្លូវកាយរបស់គាត់ទ្រុឌទ្រោម ទើបបានបង្កជាគ្រោះថ្នាក់ចរាចរណ៍ ពីព្រោះថាជាទូទៅគេអាចដឹងជាមុនបានថា នៅពេលបើកបររយៈពេលវែង និងបរិភោគអាហារមិនគ្រប់គ្រាន់ រមែងធ្វើអោយរូបកាយចុះខ្សោយ[36]។

---

[33] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៤៦។
[34] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៤៦។
[35] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៤៧។
[36] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៤៧។

### ២.២.២.កម្លាំង និងការបង្ខំត្រូវតែមិនអាចចៀសវាងបាន

កម្លាំង និងការបង្ខំដែលមិនអាចចៀសវាងបាន គឺជាកម្លាំង និងការបង្ខំដែលលុបបំបាត់ចោលទាំងស្រុងនូវសេរីភាពក្នុងការប្រព្រឹត្តអំពើ។ ចារីត្រូវស្ថិតក្នុងស្ថានភាពមិនអាចទប់ទល់លើកម្លាំងបង្ខំខាងលើ ហើយមិនអាចជ្រើសរើសអំពើណាមួយផ្សេងទៀត ក្រៅពីការប្រព្រឹត្តបទល្មើសឡើយ។ ការវាយតម្លៃអំពីលក្ខណៈចៀសវាងមិនបាននៃកម្លាំង និងការបង្ខំ គឺអាស្រ័យទៅតាមករណីនីមួយៗ ទៅតាមសម្បទារបស់ជនម្នាក់ៗក្នុងការទប់ស្កាត់នឹងកម្លាំង ឬការបង្ខំនោះ។ ដើម្បីឲ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវមានភស្តុតាងបញ្ជាក់ថា ជនប្រព្រឹត្តអំពើស្ថិតក្នុងស្ថានភាពមួយ ដែលខ្លួនមិនអាចចៀសវាងពីការប្រព្រឹត្តបទល្មើសបានទាល់តែសោះតែម្តង ឬនិយាយម្យ៉ាងទៀតថា ចារីស្ថិតក្នុងស្ថានភាព អលទ្ធភាពដាច់ខាតក្នុងការគោរពច្បាប់។ ប្រសិនបើចារីនៅមានលទ្ធភាពនឹងចៀសវាងបានខ្លះដែរ ក៏ប៉ុន្តែចារីនៅតែប្រព្រឹត្តបទល្មើសទៀត ជននេះមិនអាចលើកសំអាងពីកម្លាំង ឬការបង្ខំ ដើម្បីឲ្យបានរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ។ ជាធម្មតា ការរកភស្តុតាងមកបញ្ជាក់អំពីស្ថានភាពមិនអាចជៀសបានរមែងតែមានការលំបាកយ៉ាងខ្លាំង[37]។

**ឧទាហរណ៍:** ជនម្នាក់មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌពីបទទទួលផលចោរកម្មដោយសំអាងថា ក្រុមចោរបង្ខំរូបគាត់ឲ្យទិញវត្ថុដែលគេលួចបានក្រោមការគំរាមកំហែងថា បើមិនទិញថ្ងៃក្រោយពួកគេនឹងដុតផ្ទះរបស់គាត់ចោលជាមិនខាន។ ក្នុងករណីនេះ អំពើរបស់ក្រុមចោរ គឺជាការបង្ខំក៏ពិតមែន ក៏ប៉ុន្តែការបង្ខំនេះអាចទប់ទល់បាន តាមរយៈការប្តឹងទប់ស្កាត់ទៅអាជ្ញាធរមានសមត្ថកិច្ចជាដើម[38]។

[37] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៤៧។

[38] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៤៨។

## ជំពូកទី២.

## មូលហេតុដែលហៅថាសត្យានុម័ត ឬយុត្តិកម្មនៃបទល្មើស

អំពើមួយដែលជាធម្មតាត្រូវផ្តន្ទាទោសដោយច្បាប់ តែបែរជាត្រូវចាត់ទុកថាត្រឹមត្រូវទៅវិញ នៅពេលអំពើនោះបានបង្ហាញពីការអនុវត្តសិទ្ធិ ឬជាការបំពេញកាតព្វកិច្ច បានសេចក្តីថា អំពើនោះបានកើតឡើងដោយសារតែផលប្រយោជន៍ស្របច្បាប់ ហើយផលប្រយោជន៍នេះមានសារៈសំខាន់ជាងការចាត់ទុកអំពើនោះជាបទល្មើស[39]។ មូលហេតុស្តីពីអំពើយុត្តិកម្ម គឺជាមូលហេតុដែលគេចាត់ទុកថាចេញមកពីក្រៅបុគ្គលនៃចារី ហើយដែលធ្វើឲ្យចារីបានរួចផុតពីការទទួលខុស នឹងនាំឲ្យអ្នកផ្តើមគំនិត ឬអ្នកសមគំនិត ក៏រួចផុតពីការមិនទទួលខុសត្រូវព្រហ្មទណ្ឌដូចគ្នាទៅនឹងចារីផងដែរ[40]។

ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ មិនបានប្រើពាក្យ យុត្តិកម្មនៃបទល្មើស ឲ្យចំទេដោយគ្រាន់តែចាត់ទុកករណីទាំងបីខាងលើនេះ ជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ដូចជាវិបល្លាសស្មារតី កម្លាំងនិងការបង្ខំដែរ[41]។ នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាថ្មី បញ្ជាក់ថា អំពើអាចហៅថាជាអំពើយុត្តិកម្ម មាន៣ចំណុចគឺ ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរស្របច្បាប់(**ផ្នែកទី១**)ការការពារស្របច្បាប់ ឬសច្ចធារណ៍នៃការការពារស្របច្បាប់(**ផ្នែកទី២**) និងស្ថានភាពចាំបាច់(**ផ្នែកទី៣**)។

### ផ្នែកទី១ ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ

មាត្រា៣២ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌកម្ពុជា ចែងថា បុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្ត ឬអនុញ្ញាតតាមច្បាប់

[39] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៤៨។

[40] កៅ សីហា, *នីតិព្រហ្មទណ្ឌទូទៅ* (ភ្នំពេញ៖ អង្គរ, ២០១៣), ២៤៣។

[41] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៤៨។

បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ។
បុគ្គលណាដែលប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់
បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ
លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់។[42]

តាមអត្ថន័យខាងលើនេះ
ក្រមព្រហ្មទណ្ឌថ្មីបានបង្ហាញពីអំពើដែលត្រូវបានបញ្ញត្តិថាជាបទល្មើស
តែបែរជាមិនមែនបទល្មើសទៅវិញ
គឺដោយមូលហេតុថាអំពើនោះត្រូវបានអនុញ្ញាតដោយច្បាប់
និងមានការអនុញ្ញាតពីអាជ្ញាធរ។

ប៉ុន្តែ ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឬ បទឧក្រិដ្ឋសង្គ្រាមមិនអាចលើកលែងឲ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេទោះបីក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ៖

១. ជនល្មើសដែលបានប្រព្រឹត្តអំពើដែលបញ្ញត្តិ អនុញ្ញាត ឬមិនហាមឃាត់ជនល្មើសនោះដោយច្បាប់ជាធរមាន។

២. បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់[43]។

**ឧទាហរណ៍:**

ទោះបីជាច្បាប់ជាធរមាននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យអនុញ្ញាតឲ្យមានការសម្លាប់មនុស្សក៏ដោយ ក៏អំពើនោះត្រូវបានចាត់ទុកជា បទឧក្រិដ្ឋប្រល័យពូជសាសន៍[44] បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ[45] បទឧក្រិដ្ឋសង្គ្រាម[46] ដូច្នេះ ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតមិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ

[42] ក្រមព្រហ្មទណ្ឌកម្ពុជា, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣២ កថាខណ្ឌទី១។
[43] ក្រមព្រហ្មទណ្ឌកម្ពុជា, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣២ កថាខណ្ឌទី២។
[44] ក្រមព្រហ្មទណ្ឌកម្ពុជា, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៨៣។
[45] ក្រមព្រហ្មទណ្ឌកម្ពុជា, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៨៨។
[46] ក្រមព្រហ្មទណ្ឌកម្ពុជា, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៩៣។

ទោះបីជនល្មើសបានប្រព្រឹត្តអំពើដែលច្បាប់នាសម័យនោះបានបញ្ញាត្តិអនុញ្ញាត ឬច្បាប់មិនបានហាមឃាត់ក៏ដោយ។

យោងតាមបញ្ញត្តិក្រមព្រហ្មទណ្ឌខាងលើ អ្នកនីតិបញ្ញត្តិមានបំណងបង្កើតជាយុត្តិកម្មនូវអំពើតាមធម្មតាជាបទល្មើស ប៉ុន្តែអំពើនោះបែរជាមិនត្រូវចាត់ទុកជាបទល្មើសទៅវិញ ដោយសារតែច្បាប់អនុញ្ញាតឲ្យធ្វើ (១.១) ឬ ដោយសារតែអាជ្ញាធរស្របច្បាប់បញ្ជាឲ្យធ្វើយ៉ាងដូច្នេះ(១.២)[47]។ ក្រមព្រហ្មទណ្ឌចាស់របស់កម្ពុជា កំណត់ដែរថា មិនចាត់ទុកជាអំពើល្មើសព្រហ្មទណ្ឌទេ កាលណាបើអំពើទាំងឡាយនោះធ្វើតាមបង្គាប់របស់ច្បាប់ ហើយអ្នកបញ្ជាឲ្យធ្វើក៏ជាអាជ្ញាធរធម្មានុរូបដែរ។

**១.១. ការអនុញ្ញាតដោយច្បាប់**

រាល់អំពើទាំងឡាយណាដែលកើតចេញពីការបំពេញកាតព្វ ដែលតំរូវដោយច្បាប់ ឬ ជាការអនុវត្តសិទ្ធិដែលច្បាប់បានបញ្ញត្តិ ឬ អនុញ្ញាតឲ្យប្រព្រឹត្តអំពើនោះច្បាប់មិនបានបញ្ញត្តិឲ្យផ្តន្ទាទោសឡើយចុះពាក្យថាច្បាប់ ក្នុងមាត្រាខាងលើមានន័យយ៉ាងដូចម្តេច? ន័យទូលាយ ឬ ន័យចង្អៀត?

ន័យទូលាយ: សំដៅលើរាល់លិខិតបទដ្ឋានគតិយុត្តដែលត្រូវបានបង្កើត និងគ្រប់គ្រងទំនាក់ទំនងទាំងអស់ក្នុងសង្គម។ ន័យចង្អៀត: សំដៅលើរាល់លិខិតបទដ្ឋានគតិយុត្តដែលត្រូវបានបង្កើត និងអនុម័តឡើងដោយអង្គការនីតិបញ្ញត្តិ និងឡាយព្រះហត្ថលេខាដាក់ឲ្យប្រើប្រាស់ដោយព្រះមហាក្សត្រ។[48]

តាមនិយមន័យខាងលើទាំងពីរ ក្រមព្រហ្មទណ្ឌមិនបានបញ្ញត្តិថាជាច្បាប់ក្នុងន័យមួយណាទេ តែបើគេពិនិត្យទៅលើករណីមួយ ដែលអាចចាត់ទុកជាករណីដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ

[47] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៥៩។

[48] សេចក្តីផ្តើមនីតិកម្ពុជា ក្រោមការដឹកនាំដោយការិយាស្រាវជ្រាវរបស់ ស.ភ.ន.វ.ស។

លុះត្រាតែមានការអនុញ្ញាតពីច្បាប់ ឬ មាននៅក្នុងបញ្ញត្តិច្បាប់(ន័យចង្អៀត) ទើបករណីនោះក្លាយជាមូលហេតុដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។ **ឧទាហរណ៍:** ១. ការចាប់ខ្លួនជនសង្ស័យដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ចំពោះបទល្មើសជាក់ស្តែង[49]។ ការចាប់ខ្លួនជនសង្ស័យស្ថានភាពជាក់ស្តែងគឺត្រូវបានក្រមព្រហ្មទណ្ឌកំណត់ពីអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ទៅតាមក្របខណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែង។

គេអាចទៅយកក្រមនីតិវិធីព្រហ្មទណ្ឌ ត្រង់មាត្រា៨៧ មកពិនិត្យជាសំអាង ព្រោះច្បាប់បានអនុញ្ញាតឲ្យប្រជាពលរដ្ឋមានសិទ្ធិចាប់ខ្លួនជនល្មើស នៅក្នុងករណីប្រព្រឹត្តិបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ដើម្បីយកទៅប្រគល់ឲ្យនគរបាលយុត្តិធម៌ដែលនៅជិតបំផុត[50]។ ផ្ទុយទៅវិញនោះ ប្រសិនបើគ្មានច្បាប់ចែងយ៉ាងដូច្នេះ បែរជាប្រជាពលរដ្ឋ ឬនគរបាលយុត្តិធម៌ទៅចាប់ខ្លួនអ្នកដទៃដូចករណីខាងលើនេះ គឺជាការចាប់បង្ខាំងមនុស្សដោយខុសច្បាប់[51]។

ក្នុងមាត្រា៣២ វាក្យខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ បានចែងច្បាស់ថា បុគ្គលណាដែលប្រព្រឹត្តអំពើខុសច្បាប់ បានបញ្ញត្ត ឬអនុញ្ញាតតាមច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ។ ដូច្នេះវាក៏ប្រែក្លាយជាអំពើស្របច្បាប់ទៅវិញ ដែលជាហេតុនាំឲ្យ អ្នកប្រព្រឹត្តអំពើមួយមិនទទួលខុសត្រូវព្រហ្មទណ្ឌអ្វីសោះឡើយ[52]។ ឧទាហរណ៍: នគរបាលយុត្តិធម៌ ឬប្រជាពលរដ្ឋប្រព្រឹត្តអំពើដែលត្រូវបានបញ្ញត្តិដោយច្បាប់ ដូចជាការទៅចាប់ខ្លួនជនល្មើស។ សកម្មភាពអាជ្ញាធរ ចុះរុះរើសំណង់អនាធិបតេយ្យ ដែលត្រូវបានសាងសង់ឡើងដោយខុសច្បាប់ជាដើម។

### ១.២. ការបញ្ជាដោយអាជ្ញាធរស្របច្បាប់

[49] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៨៥។

[50] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៨៧។

[51] កៅ សីហា, *នីតិព្រហ្មទណ្ឌទូទៅ* (ភ្នំពេញ៖ អង្គរ, ២០១៣), ២៤៣។

[52] កៅ សីហា, *នីតិព្រហ្មទណ្ឌទូទៅ* (ភ្នំពេញ៖ អង្គរ, ២០១៣), ២៤៣។

ក្នុងមាត្រា៣២ វាក្យខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ ចែងថា បុគ្គលណាដែលប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់លាក់។ ក្នុងន័យនេះ ការអនុញ្ញាតដោយអាជ្ញាធរជាមូលហេតនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ លុះត្រាតែអាជ្ញាធរស្របច្បាប់(១.២.១) ជាអ្នកចេញបញ្ជាស្របច្បាប់(១.២.២)[53]។

### ១.២.១. អាជ្ញាធរស្របច្បាប់

អាជ្ញាធរស្របច្បាប់ គឺជាអ្នកទ្រទ្រង់នូវអាជ្ញា អ្នកកាន់អំណាចតាមសិទ្ធិដែលខ្លួនទទួលបានពេញលេញ។[54] ក្នុងន័យនេះ គេអាចឲ្យនិយមន័យអាជ្ញាធរស្របច្បាប់ថា គឺសំដៅលើអាជ្ញាធរសាធារណៈ ដែលអាចជាអាជ្ញាធររដ្ឋបាល អាជ្ញាធរតុលាការ ឬអាជ្ញាធរយោធា ដែលមានអំណាចតាមផ្លូវច្បាប់ក្នុងការបញ្ជាឲ្យអនុវត្តច្បាប់ និងលិខិតបទដ្ឋានផ្សេងៗទៀត។ ហេតុនេះមិនត្រូវចាត់ទុកជាអាជ្ញាធរស្របច្បាប់តាមន័យនៃមាត្រា ៣២ នៃក្រមព្រហ្មទណ្ឌកម្ពុជាឡើយចំពោះ៖ និយោជកនៃក្រុមហ៊ុនមួយ (បញ្ជាឲ្យនិយោជិតធ្វើអ្វីមួយដែលខុសត្រូវច្បាប់) ឬឪពុកម្តាយ (បញ្ជាឲ្យកូនធ្វើអ្វីមួយដែលផ្ទុយនឹងច្បាប់)។

### ១.២.២. បញ្ជាស្របច្បាប់

ក្រមព្រហ្មទណ្ឌកម្ពុជាមិនអនុញ្ញាតឲ្យជនដែលប្រព្រឹត្តបទល្មើសតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ រួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ប្រសិនបើអំពើនោះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់។ ចំពោះពាក្យថា អំពើខុសច្បាប់យ៉ាងជាក់ច្បាស់ ទាមទារឲ្យមានការវាយតម្លៃទៅតាមករណីនីមួយៗ។ ដោយត្រូវពិនិត្យទៅលើស្ថានភាពជាក់ស្តែងរបស់អ្នកទទួលបញ្ជាដូចជា សមត្ថភាព បទពិសោធន៍ និងឋានៈជាដើម។ ដូច្នេះ

---

[53] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៥៩។

[54] ទីស្តីការគណៈរដ្ឋមន្ត្រី, *សទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ*, (ភ្នំពេញ៖ ២០១១), ៧០។

មន្ត្រីរាជការថ្នាក់ខ្ពស់មានសមត្ថភាពអាចវាយតម្លៃកំណត់ពីភាពស្របច្បាប់ ឬមិនស្របច្បាប់នៃបញ្ជាណាមួយរបស់ថ្នាក់លើខ្លួនជាងមន្ត្រីធម្មតា ឬជនសាមញ្ញដែលអាជ្ញាធរបញ្ជាឲ្យធ្វើអ្វីមួយ។[55]

ការប្រើពាក្យថា អំពើខុសច្បាប់យ៉ាងជាក់ច្បាស់ នាំឲ្យសន្និដ្ឋានបានថា ប្រសិនបើអំពើដែលប្រព្រឹត្ត គ្រាន់តែជាអំពើខុសច្បាប់ ប៉ុន្តែមិនមែនជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់ទេ អ្នកទទួលបញ្ជាអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានដោយផ្អែកលើមាត្រា៣២ នៃមាត្រាព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩។[56] **ឧទាហរណ៍:** ខណៈពេលកំពុងធ្វើដំណើរលើដងវិថីមួយកន្លែង បុរសម្នាក់ត្រូវបាននគរបាលចរាចរណ៍បញ្ជាឲ្យបើកម៉ូតូទៅមុខត្រង់ ស្របពេលភ្លើងសញ្ញាចរាចរណ៍ពណ៌ក្រហម។ គេដឹងហើយថា ភ្លើងសញ្ញាចរាចរណ៍ពណ៌ក្រហម គឺជាសញ្ញាឲ្យអ្នកបើកបរត្រូវតែឈប់សិនទម្រាំភ្លើងបៃតងមកដល់ ទើបអាចធ្វើដំណើរទៅមុខបាន។ ប៉ុន្តែដោយសារតែបុរសម្នាក់នេះ ទទួលបានការអនុញ្ញាតពីនគរបាលចរាចរណ៍ ដែលជាអាជ្ញាធរស្របច្បាប់នោះ គាត់នឹងមិនត្រូវបានចោទថា ល្មើសនឹងច្បាប់ចរាចរណ៍ឡើយ បើទោះបីជាគាត់បើកបរក្នុងពេលភ្លើងសញ្ញាចរាចរណ៍ពណ៌ក្រហមក៏ដោយ។

យោងតាមក្រមព្រហ្មទណ្ឌកម្ពុជា ក៏បានបញ្ជាក់បន្ថែមទៀតថា ក្នុងករណីចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិត ក្នុងបទរបបប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋកម្មសង្គ្រាម មិនអាចលើកលែងឲ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនឡើយ បើទោះបីជាករណីមានមូលហេតុដូចជា៖

[55] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ទំព័រ?។
[56] ក្រមព្រហ្មទណ្ឌកម្ពុជា, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣២។

១. ជនល្មើសនោះបានប្រព្រឹត្តអំពើដែលបញ្ញត្ត អនុញ្ញាត ឬមិនហាមឃាត់ដោយច្បាប់ជាធរមាន។

២. បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់។[57]

គេឃើញថា បទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬបទឧក្រិដ្ឋកម្មសង្គ្រាម គឺជាបទឧក្រិដ្ឋដែលមានសភាពធ្ងន់ធ្ងរណាស់ ហើយជាឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាល។[58] ទាំងនេះជាអញ្ញត្រកម្មនៃការបង្ហាញខាងលើ ហើយដែលអ្នកប្រព្រឹត្តបទល្មើសនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។[59]

**ផ្នែកទី២ ការការពារស្របច្បាប់**

នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ការផ្ដល់និយមន័យជាក់លាក់នៃពាក្យ «ការការពារស្របច្បាប់» នៅមិនទាន់មាននៅឡើយ។ ប៉ុន្តែនៅក្នុងសទ្ទានុក្រមពាក្យច្បាប់ផ្នែកព្រហ្មទណ្ឌ ដែលចេញដោយទីស្ដីការគណៈរដ្ឋមន្ត្រី បានផ្ដល់និយមន័យថា «ការការពារស្របច្បាប់» គឺជាការតបតដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមិនត្រឹមត្រូវ ដែលការតបតនោះមិនត្រូវបានច្បាប់ចាត់ទុកថាជាបទល្មើស។[60]

ការការពារស្របច្បាប់ គឺជាសិទ្ធិរបស់ជនគ្រប់រូបមានការប្រព្រឹត្តអំពើតបតទៅបុគ្គលណាដែលបានប្រព្រឹត្តបទល្មើសមកលើខ្លួន នៅក្នុងលក្ខខណ្ឌដែលច្បាប់បានបញ្ញត្ត និងក្នុងសភាពជាការការពារស្របច្បាប់ ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ មានន័យថាចំពោះករណីណាដែលត្រូវបានប្រពឹត្តឡើងក្នុងលក្ខណៈជាការការពារស្របច្បាប់ គឺធ្វើឲ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។ នៅក្នុងករណីនេះខុសពីការអនុវត្តតាមច្បាប់ ឬតាមបញ្ជារបស់អាជ្ញាធរធម្មានរូប ដែលមិនប្រព្រឹត្តបទល្មើសឡើយ។

---

[57] សារណាបញ្ចប់ការសិក្សារបស់ ម៉ាង ណុល និង គង់ សុខហេង (ឆ្នាំ២០១២)។

[58] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៩។

[59] សារណាបញ្ចប់ការសិក្សារបស់ ម៉ាង ណុល និង គង់ សុខហេង (ឆ្នាំ២០១២)។

[60] សារណាបញ្ចប់ការសិក្សារបស់ ម៉ាង ណុល និង គង់ សុខហេង (ឆ្នាំ២០១២)។

ផ្ទុយទៅវិញនៅក្នុងករណីការពារស្របច្បាប់វិញ គឺបានន័យថាប្រព្រឹត្តបទល្មើសប៉ុន្តែមិនទទួលខុសត្រូវព្រហ្មទណ្ឌ ហើយមិនទទួលទោសព្រហ្មទណ្ឌទេបើទោះបីជាមានបទល្មើសកើតឡើងក៏ដោយ។ នេះបើយោងតាមមាត្រា៣៣ វាក្យខណ្ឌ១ បានចែងថា បុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការការពារស្របច្បាប់ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។[61]

ច្បាប់បានកំណត់នូវលក្ខខណ្ឌយ៉ាងច្បាស់លាស់ ដូចក្នុងក្រមព្រហ្មទណ្ឌ មាត្រា៣៣ វាក្យខណ្ឌទី២ បានចែងបញ្ជាក់ថា ការការពារស្របច្បាប់ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ៖

-បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវ ដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដ៏ទៃ ឬការពារទ្រព្យសម្បត្តិ ប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ

-បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងនៅក្នុងពេលជាមួយគ្នា និង

-គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន[62]។

ជាសរុបរួមមក លក្ខខណ្ឌនៃការការពារស្របច្បាប់ទាំងបីខាងលើនេះ គឺត្រូវតែផ្គុំ ឬក៏ត្រូវតែបំពេញឲ្យគ្រប់ទាំងអស់។ ទីមួយត្រូវតែមានការឈ្លានពានជាមុនហើយបទល្មើសដែល ប្រព្រឹត្តដើម្បីទប់ទល់ទៅនឹងការឈ្លានពាននោះត្រូវចាំបាច់ បានន័យថា បើសិនជាគេអាចចៀសវាងតាមមធ្យោបាយផ្សេង គឺគេចាត់ទុកថាមិនចាំបាច់ឡើយ។ ដូច្នេះគឺគេមានតែផ្លូវមួយគត់ ដើម្បីប្រព្រឹត្តបទល្មើសតទល់ជាមួយនឹងការឈ្លានពានដែលបានកើតឡើងនោះ ឬក៏ អាចនិយាយម៉្យាងទៀតបានថាគ្មានជម្រើសចុងក្រោយ ឬជម្រើសណាមួយទេ ក្រៅពីការតបតទៅវិញនេះ។ ទីពីរត្រូវតែកើតឡើងក្នុងពេលជាមួយគ្នារវាងបទល្មើស និងការឈ្លានពាន មានន័យថា ត្រូវតែតបតមកវិញភ្លាមៗតែម្តង។ និងទីបី

[61] កៅ សីហា, *នីតិព្រហ្មទណ្ឌទូទៅ* (ភ្នំពេញ៖ អង្គរ, ២០១៣), ដាក់ទំព័រ២៨៨។

[62] ក្រមព្រហ្មទណ្ឌកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៣។

ការណ៍ដែលប្រើប្រាស់នូវមធ្យោបាយការពារនោះ គឺត្រូវសមាមាត្រទៅតាមទំហំគ្រោះថ្នាក់នៃការឈ្លានពានខ្លួន នៅពេលអ្នកឈ្លានពាននោះបានរើមកលើខ្លួន ហើយអ្នកនោះបានរត់ដាក់មេព្រោចដោយបែរខ្នងទៅហើយ ស្រាប់តែអ្នកត្រូវគេរ៉ែនោះក៏ដកកាំភ្លើងបាញ់ទៀត។ នេះគឺមិនមែនស្ថិតនៅក្នុងការពារស្របច្បាប់ទេ ពីព្រោះថាអ្នកដែលបង្កការឈ្លានពាននោះបានបាត់អស់ទៅហើយ ពិសេសទម្ងន់នៃការឈ្លានពាននោះ គឺមានលក្ខណៈស្រាលទេ ហេតុនេះវាខុសគ្នាទៅនឹងទ្រឹស្តីនៃការពារទាំងស្រុងតែម្តង[63]។

សូមបញ្ជាក់នូវពាក្យថា ការការពារទ្រព្យសម្បត្តិនេះ គឺអាចការពារទាំងទ្រព្យសម្បត្តិរបស់ខ្លួនឯង និងអាចការពារទាំងទ្រព្យសម្បត្តិរបស់អ្នកដទៃទៀតផង។ មួយទៀតគឺពាក្យថា គ្មានសមាមាត្រ គឺស្មើនឹងមានតុល្យភាព ផ្ទុយទៅវិញ គ្មានតុល្យភាពគឺស្មើនឹងមានសមាមាត្រ នាំឲ្យពាក្យដែលថាគ្មានវិសមាមាត្រ ស្មើនឹងមានសមាមាត្រ ឬវិសមាមាត្រ ស្មើនឹងសមាមាត្រនេះឯង ពីព្រោះថា គ្មាន និង វិ នេះ បើតាមក្បួនគណិតសាស្ត្រ គឺយើងសម្រួលឲ្យស្មើនឹងសូន្យបាត់ហើយ ដោយសារតែយើងស៊ីសង ឬក៏ទូទាត់គ្នារួចរាល់អស់ហើយ[64]។

**ផ្នែកទី៣ សច្ចធារណ៍នៃការការពារស្របច្បាប់**

យោងតាមក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ ក្របខណ្ឌនៃការការពារស្របច្បាប់ បានកំណត់ចេញជាលក្ខខណ្ឌមួយករណីទៀត ដែលពាក់ព័ន្ធនឹងការបង្ហាញភស្តុតាង ពោលគឺជនជាប់ចោទមិនបាច់លើកសំអាង ពីការការពារស្របច្បាប់របស់ខ្លួនតាមលក្ខខណ្ឌនៃមាត្រា ៣៣ នៃក្រមព្រហ្មទណ្ឌឡើយ[65]។

---

[63] កៅ សីហា, *នីតិព្រហ្មទណ្ឌទូទៅ* (ភ្នំពេញ៖ អង្គរ, ២០១៣), ដាក់ទំព័រ២៨៨។

[64] កៅ សីហា, *នីតិព្រហ្មទណ្ឌទូទៅ* (ភ្នំពេញ៖ អង្គរ, ២០១៣), ដាក់ទំព័រ២៨៨។

[65] សារណាបញ្ចប់ការសិក្សារបស់លោក សុធា រស្មី និង លោក អៀង វណ្ណៈ (ឆ្នាំ២០១៦)។

មានករណីមួយទៀតដែលនៅក្នុងក្របខណ្ឌនៃការការពារស្របច្បាប់បានសន្មតថា ជាការការពារស្របច្បាប់តែម្តងដោយនៅក្នុងក្រមថ្មីនេះ បានកំណត់ជាសច្ចធារណ៍នៃការការពារស្របច្បាប់ បានចែងថា ត្រូវសន្មតថាជាការការពារស្របច្បាប់នៅក្នុងករណីដូចតទៅ៖

-បទល្មើសត្រូវបានប្រព្រឹត្តដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការគាស់ទម្លុះទម្លាយ ដោយហិង្សា ឬ ដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ។

-បទល្មើសបានប្រព្រឹត្តដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្តដោយហិង្សា[66]។

សច្ចធារណ៍[67] នៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ។ ហើយម៉្យាងវិញទៀតគ្រប់សកម្មភាពដែលកើតមាន ដោយសច្ចធារណ៍បែបនេះគឺអាចរំលាយទៅវិញបានដោយភស្តុតាងផ្ទុយ។[68] បញ្ហានេះគឺទាក់ទងជាមួយនឹងបន្ទុកនៃភស្តុតាង ហើយក្នុងករណីដែលច្បាប់សន្មតថាស្ថិតនៅក្នុងការការពារស្របច្បាប់ គឺបន្ទុកនៃភស្តុតាងត្រូវធ្លាក់ទៅលើស្ថាប័នមានសមត្ថកិច្ចចោទប្រកាន់។ នៅក្នុងករណីទាំងពីរខាងលើនេះ បុគ្គលដែលជាចារីនៃបទល្មើសត្រូវបានសន្មតថាស្ថិតនៅក្នុងស្ថានភាពនៃការការពារស្របច្បាប់ ដូច្នេះបុគ្គលនោះពុំបាច់នាំយកនូវភស្តុតាងបញ្ជាក់ថា លក្ខខណ្ឌនៃការការពារស្របច្បាប់នេះត្រូវបានបំពេញរួចរាល់ហើយនោះទេ ពីព្រោះថាការពារស្របច្បាប់នេះត្រូវបានសន្មតថាត្រូវបានអនុវត្តត្រឹមត្រូវហើយ[69]។

**ផ្នែកទី៤ ស្ថានភាពចាំបាច់**

[66] ក្រមព្រហ្មទណ្ឌកម្ពុជា, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៩។

[67] ទីស្តីការគណៈរដ្ឋមន្ត្រី, សន្ទានុក្រមច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌឆ្នាំ ២០១១,៦៥ សច្ចធារណ៍ មានន័យថា ការសន្មត់ទុកជាមុន។

[68] ក្រមព្រហ្មទណ្ឌកម្ពុជា, លេខ នស/រមក/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៩។

[69] សហប្រតិបត្តិការបារាំងគំពោងទ្រទ្រង់នីតិរដ្ឋ, *មេរៀននីតិព្រហ្មទណ្ឌខ្មែរ*(២០០៨), ៣៧។

ស្ថានភាពចាំបាច់ ជាករណីដែលមនុស្សម្នាក់ចង់គេចផុតពីគ្រោះអាសន្នជាក់ស្តែងមួយដែលកំពុងគម្រាមកំហែងផលប្រយោជន៍របស់រដ្ឋ ផលប្រយោជន៍ស្របច្បាប់របស់ខ្លួន ឬ របស់អ្នកដទៃក្នុងការលៈទេសៈដែលពុំមានវិធីណាផ្សេង ក្រៅពីការធ្វើសកម្មភាពដែលបង្កឲ្យមានការអន្តរាយមួយមានទំហំតូចជាងការអន្តរាយដែលត្រូវបានទប់ស្កាត់ ។ ការបង្កឲ្យមានការអន្តរាយក្នុងស្ថានភាពនេះពុំមែនជាបទល្មើសឡើយ ។[70] នៅចំពោះមុខស្ថានភាពមួយដែលទាមទារឲ្យមនុស្ស ត្រូវជំនះឲ្យបាននូវគ្រោះអាសន្នដែលកំពុងគម្រាមកំហែងដល់បណ្តាផលប្រយោជន៍ស្របច្បាប់ ហើយមានវិធីតែមួយគត់គឺការបង្កឲ្យមានការអន្តរាយដល់ផលប្រយោជន៍ផ្សេងទៀតដែលក្រមព្ទហ្មទណ្ឌបានការពារ ហើយទំហំនៃការអន្តរាយត្រូវតែតូចជាងការអន្តរាយដែលគេបានទប់ស្កាត់[71]។ ជារួម ស្ថានភាពចាំបាច់ គឺជាស្ថានភាពពិសេស ដែលមិនអាចខកខានបានដោយជៀសមិនផុតពីការប្រព្រឹត្តអ្វីមួយ[72]។ បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្ត មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

- បទល្មើសត្រូវបានចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន និង
- គ្មានសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់។[73]

បើគេប្រៀបធៀបកម្មវត្ថុនៃការការពារនៅក្នុងស្ថានភាពចាំបាច់ គឺដូចគ្នាទៅនឹងករណីនៃការការពារស្របច្បាប់ បានន័យថាដូចទាំងការពារខ្លួន ដូចទាំងការពារអ្នកដទៃ និងដូចទាំងការពារទ្រព្យសម្បត្តិផងដែរ។

[70] សារណាបញ្ចប់ការសិក្សារបស់ លោក សុធា រស្មី និង លោក អៀង វណ្ណៈ (ឆ្នាំ២០១៦)។

[71] ជួន ប៊ុនធី, នីតិព្រហ្មទណ្ឌទូទៅ។

[72] ទីស្តីការគណៈរដ្ឋមន្ត្រី, សន្ទានុក្រមច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌឆ្នាំ ២០១១, ៦៧។

[73] ក្រមព្រហ្មទណ្ឌកម្ពុជា, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៥។

ប៉ុន្តែអ្វីដែលស្ថានភាពចាំបាច់ខុសគ្នា ស្រលះពីការការពារស្របច្បាប់ គឺដោយសារចារីប្រឈមនឹងគ្រោះថ្នាក់មួយ ដែលមិនកើតចេញពីការឈ្លានពានមិនត្រឹមត្រូវនោះទេ។ ចំណែកឯនៅក្នុងការការពារស្របច្បាប់ គឺត្រូវតែមានការឈ្លានពានខុសច្បាប់ ឬកើតចេញពីការឈ្លានពានមួយដែលមិនត្រឹមត្រូវទេ។ រីឯនៅក្នុងស្ថានភាពចាំបាច់ គឺចារីស្ថិតនៅប្រឈមចំពោះគ្រោះថ្នាក់មួយ ដែលអាចកើតចេញដោយឯកឯង ក៏ប៉ុន្តែមិនមែនកើតចេញពីការឈ្លានពានមួយដែលមិនត្រឹមត្រូវឡើយ។ ចំណុចមួយទៀតនោះគឺថាស្ថានភាពចាំបាច់ខុសទៅនឹងអានុភាពនៃកម្លាំងបង្ខំ ឬការបង្ខំ ដោយសារតែនៅក្នុងស្ថានភាពចាំបាច់នេះ គឺចារីគាត់មានសេរីភាពនៅក្នុងជម្រើសរបស់ខ្លួនគាត់។ ចំណែកឯនៅក្នុងស្ថានភាពស្ដីពីអានុភាពនៃកម្លាំង ឬការបង្ខំ គឺចារីគាត់មិនអាចទប់ទល់បានហើយ និងគ្មានជម្រើសនោះទេ។ ដូច្នេះហើយ នៅក្នុងស្ថានភាពចាំបាច់ គឺចារីគាត់មានសេរីភាពនៅក្នុងការប្រព្រឹត្ត ឬក៏មិនប្រព្រឹត្តទេ។[74]

ស្ថានភាពចាំបាច់ គឺជាស្ថានភាពរបស់បុគ្គលម្នាក់ដែលឈានទៅដល់ការប្រព្រឹត្តបទល្មើសណាមួយ ដោយសារតែមានបំណងចង់ស្តារនូវផលប្រយោជន៍មួយផ្សេងទៀត ដែលត្រូវបានគំរាមកំហែងដោយគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន។ ចំពោះស្ថានភាពចាំបាច់ ចារីមានជម្រើសពីរយ៉ាងគឺ:

-ទទួលយកការខូចខាតដែលនឹងត្រូវកើតមានឡើង ដោយសុខចិត្តបដិសេធមិនព្រមប្រព្រឹត្តបទល្មើស។

-ត្រូវតែប្រព្រឹត្តបទល្មើសដើម្បីបញ្ចៀសការខូចខាត។[75]

ស្ថានភាពចាំបាច់ធ្វើឲ្យកើតនូវវិវាទផលប្រយោជន៍ ដែលតម្រូវឲ្យបុគ្គលម្នាក់ជ្រើសរើសជាចាំបាច់ ដើម្បីការពារផលប្រយោជន៍ណាមួយ

---

[74] កៅ សីហា, *នីតិព្រហ្មទណ្ឌទូទៅ* (ភ្នំពេញ៖ អង្គរ, ២០១៣), ២៥៤។

[75] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៧០។

ដោយខានមិនបាន។ ក្នុងន័យនេះ ស្ថានភាពចាំបាច់ខុសប្លែកពីកម្លាំង និងការបង្ខំដែលជំរុញឲ្យចារីប្រព្រឹត្តបទល្មើស ពីព្រោះតែខ្លួនមិនអាចទប់ទល់បាន ដោយគ្មានជម្រើសអ្វីដែលល្អទាល់តែសោះ។[76]

អ្វីដែលស្ថិតជាចម្បងនៅក្នុងស្ថានភាពចាំបាច់ គឺជាជញ្ជីងមួយរវាងផលប្រយោជន៍ដែលការពារ និងផលប្រយោជន៍ដែលត្រូវលះបង់។ ហេតុនេះផលប្រយោជន៍ដែលត្រូវការពារ ត្រូវតែជាផលប្រយោជន៍ដែលត្រូវលះបង់ ដែលនេះគឺជាជញ្ជីងដែលត្រូវបានថ្លឹងនៅក្នុងស្ថានភាពចាំបាច់។[77]

ដើម្បីឲ្យស្ថានភាពចាំបាច់ក្លាយជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ជនដែលបានប្រព្រឹត្តបទល្មើសត្រូវបង្ហាញភស្តុតាងអំពីអត្ថិភាពនៃគ្រោះថ្នាក់កំពុងមាន ឬដែលនឹងកើតមាន (៤.១) និងការការពារនេះត្រូវតែសមាមាត្រជាមួយនឹងទម្ងន់នៃគ្រោះថ្នាក់ (៤.១)។

### ៤.១. គ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន

ជាដំបូងជនប្រព្រឹត្តបទល្មើសដោយសារស្ថានភាពចាំបាច់ ត្រូវរកភស្តុតាងអំពីគ្រោះថ្នាក់ ដែលជំរុញឲ្យខ្លួនប្រព្រឹត្តបទល្មើស។ គ្រោះថ្នាក់នេះអាចជាគ្រោះថ្នាក់ដែលគំរាមកំហែងតតិយជន ឬមួយក៏គ្រាន់តែជាគំរាមកំហែងលើទ្រព្យសម្បត្តិណាមួយក៏បានដែរ។[78] ឧទាហរណ៍: ដើម្បីកុំឲ្យសម្ភាររបស់ខ្លួនត្រូវភ្លើងឆេះ បុរសម្នាក់បានចូលទៅផ្ទះអ្នកដទៃយកវត្ថុពន្លត់អគ្គិភ័យបាញ់ភ្លើងពន្លត់។ ក្នុងស្ថានភាពដែលកំពុងកើតឡើងចំពោះចារីផ្ទាល់បែបនេះ ចារីមិនត្រូវបានចាត់ទុកថាលួចទ្រព្យសម្បត្តិអ្នកដទៃឡើយ។ ដើម្បីជួយសង្គ្រោះជីវិតរបស់មនុស្សដែលកំពុងត្រូវភ្លើងឆេះដូចគ្នា បុរសម្នាក់បានចូលទៅក្នុងផ្ទះអ្នកដទៃ ដើម្បីលួចយកវត្ថុពន្លត់ភ្លើងបាញ់លើបុរសម្នាក់នោះ។

---

[76] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៧០។

[77] កៅ សីហា, *នីតិព្រហ្មទណ្ឌទូទៅ* (ភ្នំពេញ៖ អង្គរ, ២០១៣), ២៥៥។

[78] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៧០។

ករណីបែបនេះចោរីបានចូលទៅក្នុងផ្ទះអ្នកដទៃដោយគ្មានការអនុញ្ញាត ប៉ុន្តែច្បាប់កំណត់ថាមិនខុសនោះឡើយ ព្រោះទង្វើរបស់ចោរីស្តែងឲ្យឃើញពីការជួយអ្នកដទៃ។

គ្រោះថ្នាក់ត្រូវតែមានជាក់លាក់ មានន័យថា ជាគ្រោះថ្នាក់កំពុងមាន ឬដែលនឹងកើតមានយ៉ាងពិតប្រាកដ មិនមែនគ្រោះថ្នាក់ជាយថាហេតុតាមការរវើយរវាយ ឬតាមការប៉ាន់ស្មានជាអត្តនោម័តរបស់ចោរីឡើយ។ ហេតុដូច្នេះការវាយតម្លៃអំពីគ្រោះថ្នាក់ដែលនឹងកើតមានត្រូវធ្វើឡើងដោយលក្ខណៈសត្យានុម័ត មិនអាចទាញចេញពីការភ័យព្រួយបារម្ភរបស់ចោរីតែម្នាក់ឯងបានឡើយ។[79] **ឧទាហរណ៍:** បុរសម្នាក់បានលួចអាហារគេបរិភោគ ដោយអះអាងថាមកពីខ្លួនឃ្លាន។ ទង្វើនេះបានសម្តែងឲ្យឃើញពីចោរីម្នាក់នោះ ដោយសារការលួចអាហាររបស់គេ។ បើសិនចោរីពិតជាឃ្លានមែន គាត់អាចសុំគេដោយភាពសុចរិតទើបគ្មានកំហុស។

### ៤.២. គ្មានវិសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់

ចោរីត្រូវរកភស្តុតាងមកបញ្ជាក់ឲ្យឃើញថា បទល្មើសដែលខ្លួនបានប្រព្រឹត្តថាមានលក្ខណៈសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃគ្រោះថ្នាក់។ ផលវិបាកនៃបទល្មើសត្រូវតែមានតម្លៃតិចជាង ឬស្មើនឹងតម្លៃដែលចោរីមានបំណងចង់ស្រោចស្រង់សង្គ្រោះ។ ភាពសមាមាត្រនៃមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់ត្រូវវាយតម្លៃទៅតាមស្ថានភាពនៃករណីនីមួយៗ។[80]

**ឧទាហរណ៍:** បុរសម្នាក់បានសម្រេចចិត្តបើករថយន្តទៅបុកបង្គោលភ្លើង ដោយសារចង់គេចចេញពីក្មេងប្រុសម្នាក់ដែលរត់លើផ្លូវថ្នល់។ ករណីបែបនេះចោរីមិនត្រូវបានចោទប្រកាន់ថា បំផ្លាញទ្រព្យសម្បត្តិសាធារណៈឡើយ។ គេសង្កេតឃើញថា បើបុរសម្នាក់នោះមិនបើកបុកបង្គោលភ្លើងទេ ជីវិតក្មេងអាចនឹងបាត់បង់ដោយសារឡានរបស់ខ្លួន។

---

[79] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៧២។

[80] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៧៤។

ជាក់ស្តែងជីវិតមនុស្សថ្លៃជាងអ្វីៗទាំងអស់ ហេតុនេះគាត់ត្រូវតែរួចផុតពីការទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនយ៉ាងពិតប្រាកដ។

គួរកត់សម្គាល់ជាចុងក្រោយថា ក្រមរដ្ឋប្បវេណីបានចែងពីស្ថានភាពផងដែរ។ យោងតាមមាត្រា៧៥៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីបានកំណត់និយមន័យនៃស្ថានភាពចាំបាច់ថា អំពើដោយស្ថានភាពចាំបាច់សំដៅទៅលើអំពើរំលោភដែលពុំអាចចៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬទ្រព្យសម្បត្តិរបស់ខ្លួន ឬអ្នកដទៃចំពោះគ្រោះថ្នាក់បច្ចុប្បន្ន ឬអច្ចាសន្ន[81] ហើយដែលស្ថិតក្នុងតុល្យភាពរវាងវិធីការពារ និងកម្រិតគ្រោះថ្នាក់នោះ។[82] យោងតាមខ្លឹមសារនៃបញ្ញត្តិនេះ ស្ថានភាពចាំបាច់តាមក្រមរដ្ឋប្បវេណី មិនខុសពីស្ថានភាពចាំបាច់តាមក្រមព្រហ្មទណ្ឌឡើយ។ យោងតាមមាត្រា៧៥៦ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីចំពោះការកើតមានឡើង ដោយស្ថានភាពចាំបាច់ អ្នកដែលបានប្រព្រឹត្តបទល្មើសដោយសារស្ថានភាពចាំបាច់ពុំទទួលខុសត្រូវឡើយ។ ក្នុងករណីនេះ បុគ្គលដែលបានប្រព្រឹត្តអំពើផ្ទុយច្បាប់ដែលជាមូលហេតុនៃអំពើនោះ ត្រូវទទួលខុសត្រូវ។ ហេតុដូច្នេះតាមក្រមរដ្ឋប្បវេណីនៃកម្ពុជា បុគ្គលដែលបានប្រព្រឹត្តបទល្មើសដោយសារស្ថានភាពចាំបាច់ មិនទទួលខុសត្រូវក្នុងការសងការខូចខាតឡើយ ក៏ប៉ុន្តែជនដែលបានបង្កឲ្យមានការប្រព្រឹត្តបទល្មើស គឺជាអ្នកទទួលខុសត្រូវទៅវិញ។[83]

[81] អច្ចាសន្ន មានន័យថា គ្រោះថ្នាក់ដែលហៀបនឹងកើតឡើងយ៉ាងពិតប្រាកដ។

[82] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៧៥៥ កថាខណ្ឌទី២។

[83] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៧៥។

# ជំពូកទី៣.

# មូលហេតុផ្សេងទៀត

## ផ្នែកទី១ មូលហេតុទាក់ទងនឹងនីតិភាព

ជាគោលការណ៍ គេមិនអាចឲ្យជនដែលមិនដឹងខុសត្រូវពីភាពធ្ងន់ធ្ងរនៃអំពើរបស់ខ្លួនឲ្យទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ការយល់ដឹងខុសត្រូវជាកត្តាមួយដែលនាំឲ្យបុគ្គលម្នាក់ៗ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។ ប្រសិនបើក្មេងអាយុ៥ឆ្នាំម្នាក់ បានចាក់សម្លាប់ក្មេងម្នាក់ទៀត ក្មេងដែលបានប្រព្រឹត្តអំពើល្មើសមិនអាចទទួលខុសត្រូវ ព្រហ្មទណ្ឌបានទេ ដោយសារតែក្មេងអាយុ៥ឆ្នាំនោះ មិនមានសមត្ថភាពដឹងខុសត្រូវពីអំពើរបស់ខ្លួនឡើយ។ ដោយឡែកចំពោះអនីតិជនដែលមានអាយុ៥ឆ្នាំវិញ ការអះអាងថាអនីតិជននោះមិនដឹងខុសត្រូវទាល់តែសោះនោះ គឺជាអំណោះអំណាងមួយដែលនឹងពិបាកទទួលយកបាន។[84] យ៉ាងណាមិញ មាត្រា៣៨ នៃក្រមព្រហ្មទណ្ឌ កំណត់នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌគឺនៅត្រឹមអាយុ១៨ឆ្នាំឡើងទៅ។[85]

ក្នុងន័យបញ្ញត្តិនៃមាត្រា៣៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០១៩ អនីតិជនដែលមានអាយុតិចជាង១៨ឆ្នាំ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។[86] ថ្វីត្បិតតែអនីតិជនមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ក៏ប៉ុន្តែក្រមព្រហ្មទណ្ឌតម្រូវឲ្យមានវិធានការតាមដាន វិធានការការពារ និងវិធានការឧបត្ថម្ភ

[84] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៣១។

[85] ក្រមព្រហ្មទណ្ឌកម្ពុជា, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៨។

[86] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៣១។

សម្រាប់អនីតិជនដែលប្រព្រឹត្តបទល្មើស។ ដូច្នេះប្រសិនបើអនីតិជនបានប្រព្រឹត្តបទល្មើស ជាគោលការណ៍គេប្រើវិធានការតាមដាន អប់រំ ការពារ និងឧបត្ថម្ភចំពោះ អនីតិជននោះ (១.១) មិនតែប៉ុណ្ណោះប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ ក្រមព្រហ្មទណ្ឌអនុញ្ញាតឲ្យតុលាការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌ ទៅលើអនីតិជនចាប់ពីអាយុ១៤ឆ្នាំឡើងទៅបាន ដោយអនីតិជនត្រូវតែទទួលការផ្តន្ទាទោសដោយឡែក (១.២)។[87]

## ១.១. វិធានការអនុវត្តន៍ចំពោះអនីតិជន

អនីតិជន ជាជនដែលច្បាប់មិនទាន់ឲ្យទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្ត និងជាជនដែលច្បាប់កំណត់ឲ្យទទួលខុសត្រូវលើអំពើរបស់ខ្លួនដោយមានកម្រិត[88]។ អនីតិជន គឺជាជនដែលមានអាយុដែលច្បាប់កំណត់ថា ជាជនមិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ព្រោះជាជនដែលមិនអាចយល់ដឹងពីសកម្មភាព ឬអំពើដែលខ្លួនបានប្រព្រឹត្តថា ជាបទល្មើសព្រហ្មទណ្ឌឡើយ។ ទោះបីជាច្បាប់បានកំណត់ថាអនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ មិនត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក៏ដោយ តែក៏នៅមានវិធានការមួយចំនួនសម្រាប់អនុវត្តចំពោះនីតិជននោះផងដែរ។ យោងតាមមាត្រា៣៩ ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ កំណត់ថា អនីតិជនប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ[89]។

មាត្រា៤០ ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ដដែល កំណត់ពីវិធានការតាមដាន វិធាននការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ដូចតទៅ៖

[87] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៣២។

[88] ទីស្តីការគណៈរដ្ឋមន្ត្រី, សន្ទានុក្រមច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌឆ្នាំ ២០១១,៦៩។

[89] ក្រមព្រហ្មទណ្ឌកម្ពុជា, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៩ កថាខណ្ឌទី១។

១. ការប្រគល់អនីតិជនឲ្យទៅឪពុកម្ដាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត។

២. ការប្រគល់អនីតិជនឲ្យទៅសេវាសាធារណដែលសម្រាប់ទទួលបន្ទុកឲ្យអនីតិជន។

៣. ការប្រគល់អនីតិជនឲ្យទៅអង្គការឯកជនដែលមាននីតិសម្បទា ក្នុងការទទួលអនីតិជន។

៤. ការប្រគល់អនីតជនឲ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស។

៥. ការដាក់អនីតិជនឲ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។

ក្នុងករណីដែលអនីតិជនដាក់ឲ្យស្ថិតក្រោមការការពាររបស់តុលាការនោះ តុលាការចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន។ បុគ្គលនេះធ្វើរបាយការណ៍ ស្ដីពីកិរិយាមាយាទរបស់អនីតិជនឲ្យបានទៀតទាត់ដល់ព្រះរាជអាជ្ញា អំពីព្រឹត្តិការណ៍ទាំងអស់ដែលអាចនាំឲ្យមានការកែប្រែនូវវិធានការនេះ។

មាត្រាទាំងពីរគឺបានបង្ហាញនូវវិធានការ ដែលសម្រាប់អនុវត្តទៅលើអនីតិជនដើម្បីអប់រំ កែប្រែចំពោះអនីតិជនដែលបានប្រព្រឹត្តបទល្មើស និងដើម្បីធ្វើអោយអនីតិជននោះក្លាយជាអនីតិជនដ៏ល្អនៅក្នុងសង្គម ហើយយលងមិនអាចផ្តន្ទាទោសណាមួយឡើយ បើទោះបីជាអនីតិជននោះបានប្រព្រឹត្តបទល្មើសប្រភេទណាក៏ដោយ។ តាមខ្លឹមសារនៃមាត្រា៣៩ និងមាត្រា៤០ នៃក្រមព្រហ្មទណ្ឌខាងលើនេះ តុលាការជាស្ថានប័នមានសមត្ថកិច្ចក្នុងការចាត់វិធានការដែលបានរៀបរាប់នៅក្នុងមាត្រា៤០ នៃក្រមព្រហ្មទណ្ឌ ក៏ប៉ុន្តែក្រមព្រហ្មទណ្ឌក៏ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌពុំបានចែងលម្អិតអំពីនីតិវិធីពិសេសសម្រាប់ចាត់វិធានការទាំងអស់នេះឲ្យមានប្រសិទ្ធភាពនោះទេ។[៩០]

នីតិវិធីនៃការឃាត់ខ្លួនរបស់អនីតិជនមានលក្ខណៈពិសេស

[៩០] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៣៣។

មិនដូចជាការឃាត់ខ្លួននីតិជនឡើយ ពោលគឺ ពុំមានការពន្យាពេលនៃការឃាត់ខ្លួនឡើយបើសិនបុគ្គលដែលឃាត់ខ្លួននោះជានីតិជន[91] ។

**១.២. ទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជន**

សម្រាប់អនីតិជនចាប់ពីអាយុចាប់ពី១៤ឆ្នាំឡើងទៅ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌបាន។ ទណ្ឌកម្មព្រហ្មទណ្ឌដែលក្រមព្រហ្មទណ្ឌសំដៅដល់ គឺទោសនេះតែម្តង។[92] ការកំណត់អាយុ១៤ឆ្នាំ សម្រាប់លទ្ធភាពនៃការប្រកាសទណ្ឌកម្ម ស្របទៅនឹងបទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌដែលអនុញ្ញាតឲ្យមានការឃុំខ្លួនជនត្រូវចោទ ឬជនជាប់ចោទជាបណ្តោះអាសន្ន ចំពោះអនីតិជនចាប់ពី១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំ ក្នុងលក្ខណ្ឌកំណត់ដោយច្បាប់ និងក្នុងចិរវេលាមួយតិចជាងការឃុំខ្លួនបណ្តោះអាសន្នលើនីតិជន[93]។ ចំណែកឯអនីតិជនអាយុក្រោម១៤ឆ្នាំវិញ មិនអាចត្រូវទទួលរងនូវការផ្តន្ទាទោសណាមួយឡើយ ទោះបីជាអនីតិជននោះបានប្រព្រឹត្តិបទល្មើសប្រភេទណាក៏ដោយ ក៏ប៉ុន្តែតុលាការអាចចាត់វិធានការណាមួយដូចមានចែងនៅក្នុងមាត្រា៤០ នៃក្រមព្រហ្មទណ្ឌបាន[94]។

យោងតាមមាត្រា៣៩ ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០១៩ កំណត់ថា កំណត់ថា អនីតិជនប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ។ ប៉ុន្តែតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនចាប់ពីអាយុ១៤ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ[95]។

---

[91] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៩៦។

[92] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ,* កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៣៣។

[93] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា២១៣ និងមាត្រា២១៤។

[94] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ,* កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៣៤។

[95] ក្រមព្រហ្មទណ្ឌកម្ពុជា, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៩។

បន្ថែមពីនេះទៅទៀត បញ្ញាត្តិនៃក្រមព្រហ្មទណ្ឌស្តីពីការមិនរាងចាល មិនអាចយកមកអនុវត្តបានឡើយចំពោះអនីតិជន បើទោះបីជាអនីតិជននោះបានប្រព្រឹត្តក្នុងស្ថានភាពមិនរាងចាលក៏ដោយ[96]។

ក្រមព្រហ្មទណ្ឌពុំបានកំណត់និយមន័យ ឬបុគ្គលិកលក្ខណៈរបស់អនីតិជន ដែលជាលក្ខខណ្ឌនៃការប្រកាសទោសទៅលើអនីតិជនឡើយ។ ក្នុងន័យនេះ តុលាការវិនិច្ឆ័យទៅតាមរឿងក្តីនីមួយៗថា តើមានលក្ខណ្ឌតម្រូវឲ្យប្រកាសទោសទៅលើអនីតិជនដែរឬទេ។[97]

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី១៨ឆ្នាំឡើងទៅ។ ដូច្នេះ ក្រោមអាយុ១៨ឆ្នាំ ជាគោលការណ៍ គឺមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ប៉ុន្តែអញ្ញាត្រកម្ម ឬករណីលើកលែង ឬករណីពិសេសមួយចំនួន តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី១៤ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនដែលជាជនល្មើសតម្រូវ ដូចជាស្ថិតនៅក្នុងស្ថានភាពឃោរឃៅ ឬមួយប្រព្រឹត្តជាប្រចាំ ឬក៏អនីតិជននោះមានអាយុ១៤ឆ្នាំក៏ពិតមែន ប៉ុន្តែមានការរីកធំធាត់ដូចមនុស្សពេញវ័យ។ ដូច្នេះតុលាការអាចប្រកាសទោស ក៏ប៉ុន្តែទោសដែលប្រកាសចំពោះអនីតិជនអាយុចាប់ពី១៤ឆ្នាំនោះ មានលក្ខណៈស្រាលជាងទោសដែលប្រកាសសម្រាប់នីតិជន។ តែបើអនីតិជនមានអាយុក្រោម ១៤ឆ្នាំ ឬ១៣ឆ្នាំ ១១ខែ ២៩ថ្ងៃ គឺអត់មានទទួលខុសត្រូវព្រហ្មទណ្ឌ ឬទទួលនូវទណ្ឌកម្មព្រហ្មទណ្ឌណាមួយឡើយ។[98]

នៅក្នុងក្រមព្រហ្មទណ្ឌ បានបញ្ញត្តិយ៉ាងជាក់លាក់ចំពោះទោសដែលត្រូវអនុវត្តទៅលើអនីតិជន

[96]ក្រមព្រហ្មទណ្ឌកម្ពុជា, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៦៣។

[97] រុន ពណ្ណារិទ្ធ, *នីតិព្រហ្មទណ្ឌទូទៅ*, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៣៩។

[98] កៅ សីហា, *នីតិព្រហ្មទណ្ឌទូទៅ* (ភ្នំពេញ៖ អង្គរ, ២០១៣), ២៤២។

កាលណាតុលាការសម្រេចផ្តន្ទាទោសទៅលើអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ គឺមូលហេតុលើការចោទប្រកាន់ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ៖

១.អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល។

២.ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ២០ឆ្នាំ។

៣.អប្បរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បរមានោះលើសពី១ថ្ងៃ។

៤.អប្បរមា និងអតិបរមានៃទោសពិន័យជាប្រាក់ត្រូវបន្ថយពាក់កណ្តាល[99]។

ដូច្នេះ ការកំណត់ទោសដែលយកមកអនុវត្តលើអនីតិជន ត្រូវបន្ថយពាក់កណ្តាលដូចមានចែងក្នុងមាត្រាខាងលើ។

**ផ្នែកទី២ មូលហេតុទាក់ទងនឹងនីតិបុគ្គល**

ទោះបីជាច្បាប់បានកំណត់អំពីគោលការណ៍ នៃការទទួលខុសត្រូវព្រហ្មទណ្ឌក៏ដោយ ក៏ច្បាប់បានកំណត់អំពីគោលការណ៍អញ្ញត្រកម្មមួយចំនួន ដែលអនុញ្ញាតឲ្យនីតិបុគ្គលអាចមិនទទួលខុសត្រូវព្រហ្មទណ្ឌបានដែរ។ នីតិបុគ្គលគឺជាក្រុមមនុស្ស ឬមូលនិធិដែលមានបុគ្គលភាពគតិយុត្ត ហើយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច[100]។

មូលហេតុទាក់ទងនឹងនីតិបុគ្គលរួមមាន ការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ដែលប្រព្រឹត្តដោយរូបវន្តបុគ្គល ឬហៅថានីតិបុគ្គលឯកជន (២.១) និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់រដ្ឋ ឬហៅថានីតិបុគ្គលសាធារណៈ (២.២)។

**២.១. ការមិនទទួលខុសត្រូវរបស់នីតិបុគ្គលឯកជន**

[99] ក្រមព្រហ្មទណ្ឌកម្ពុជា, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៦០។

[100] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៩, មាត្រា ៩៦ កថាខណ្ឌទី១។

នីតិបុគ្គលឯកជន ជាបណ្តុំនៃរូបវន្តបុគ្គលដែលបង្កើតឡើងដោយច្បាប់ក្នុងគោលដៅស្វែងរកផលចំនេញ និងបម្រើផលប្រយោជន៍រូបវន្តបុគ្គលដែលជាសមាជិករបស់ខ្លួន។ **ឧទាហរណ៍:** ក្រុមហ៊ុន សមាគម សហជីប អង្គការក្រៅរដ្ឋាភិបាល ឬ អង្គការអន្តរជាតិផ្សេងៗ។ល។ ក្នុងករណីដែលអំពើមួយប្រព្រឹត្តឡើងដោយតំណាងនៃនីតិបុគ្គលនោះ ប៉ុន្តែដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន ឬជាផលប្រយោជន៍សម្រាប់អ្នកដទៃ គឺច្បាប់មិនដាក់ទណ្ឌកម្មទៅលើនីតិបុគ្គលនោះឡើយ ឬក៏ក្នុងករណីដែលបុគ្គលដែលជាតំណាងឲ្យនីតិបុគ្គលនោះ បានប្រព្រឹត្តបទល្មើសស្ថិតនៅក្នុងមូលហេតុ នៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ដែលមានចែងក្នុងមាត្រា៣១ ដល់មាត្រា៣៧ នៃក្រមព្រហ្មទណ្ឌកម្ពុជា ដូចជាការមិនទទួលខុសត្រូវដោយសារមូលហេតុវិបល្លាសស្មារតី ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ ការការពារស្របច្បាប់ សច្ចធារណ៍នៃការការពារស្របច្បាប់ ស្ថានភាពចាំបាច់ និងអនុភាពនៃកម្លាំង ឬការបង្ខំ ទង្វើទាំងអស់នេះក៏ត្រូវគេសន្មតថា នីតិបុគ្គលនោះនឹងមិនទទួលខុសត្រូវក្នុងរឿងព្រហ្មទណ្ឌដែរ។ និយាយដោយរួមការដាក់ឲ្យនីតិបុគ្គលណាម្នាក់ទទួលខុសត្រូវក្នុងរឿងព្រហ្មទណ្ឌ លុះត្រាតែមានអំពើជាចេតនារបស់រូបវន្តបុគ្គលមួយ ដែលជាតំណាងឲ្យនីតិបុគ្គលនោះបានប្រព្រឹត្តបទល្មើស ដើម្បីជាផលប្រយោជន៍សម្រាប់នីតិបុគ្គល ហើយត្រូវតុលាការផ្តន្ទាទោសចំពោះរូបវន្តបុគ្គលនោះ ទើបតុលាការប្រកាសអំពីទោសចំពោះនីតិបុគ្គលនោះបាន ក្នុងករណីដែលមានច្បាប់បានចង្អុលបង្ហាញជាក់លាក់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល។

ដើម្បីឲ្យនីតិបុគ្គលឯកជនអាចទទួលខុសត្រូវព្រហ្មទណ្ឌ គឺទាល់តែចូលលក្ខខណ្ឌដែលថានីតិបុគ្គលនេះបានប្រព្រឹត្តបទល្មើសណាមួយ ដោយធ្វើតាមរយៈតំណាងរបស់គាត់ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល គឺមិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ (វាអាចពាក់ព័ន្ធទៅនឹងមាត្រា១៨ នៃក្រមព្រហ្មទណ្ឌ)។[101] មាត្រា១៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា ចែងថា ការដាក់ឈ្មោះបទល្មើសដែលប្រព្រឹត្តដោយនីតិបុគ្គលថាជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ត្រូវកំណត់ដោយទណ្ឌកម្មដែលទទួលរងដោយរូបវន្តបុគ្គល។

ក្រុមហ៊ុនមួយបង្កើតឡើងដែលមានភ្នាក់ងាររបស់គាត់ ឬមួយក៏តំណាងរបស់គាត់បានទៅធ្វើសកម្មភាពដើម្បីជាប្រយោជន៍ដូចជា ទៅប្រើប្រាស់នូវគ្រប់មធ្យោបាយនានា រៀបចំដើម្បីទៅធ្វើឲ្យសាធារណៈជនយល់ច្រឡំរួចក៏បង់នូវប្រាក់កាស ឬទ្រព្យសម្បត្តិផ្សេងៗ ដែលគាត់យកមកធ្វើជាប្រយោជន៍សម្រាប់នីតិបុគ្គល។ ដូច្នេះគឺយើងកំណត់ថា គាត់បានធ្វើអំពើឆបោកសាធារណៈជន ដែលធ្វើឡើងបែបនេះ គឺថានីតិបុគ្គលប្រព្រឹត្តបទល្មើស។ ប៉ុន្តែដើម្បីឲ្យនីតិបុគ្គលនេះអាចទទួលខុសត្រូវព្រហ្មទណ្ឌបាន ទាល់តែមានច្បាប់ ឬបទដ្ឋានគតិយុត្តចែងជាក់លាក់ថា នីតិបុគ្គលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ តែបើសិនជាមិនមានចែងទេ យើងមិនអាចឲ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ហើយមិនមែនអំពើទាំងអស់ដែលធ្វើឡើងមកនោះ គឺសុទ្ធតែឲ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌទេ។[102] នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ ចែងចំណុចពាក់ព័ន្ធទៅនឹងបទល្មើសមួយៗនោះដោយកំណត់ថា តើបទល្មើសណាខ្លះដែលនីតិបុគ្គលត្រូវទទួលខុសត្រូវ។ ផ្ទុយទៅវិញ បើសិនជាបទល្មើសណាមួយមិនមានចែងឲ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌទេ

[101] កៅ សីហា, *នីតិព្រហ្មទណ្ឌទូទៅ* (ភ្នំពេញ៖ អង្គរ, ២០១៣), ២០៤។

[102] កៅ សីហា, *នីតិព្រហ្មទណ្ឌទូទៅ* (ភ្នំពេញ៖ អង្គរ, ២០១៣), ២០៥។

គឺអត់ត្រូវដាក់ទណ្ឌកម្មព្រហ្មទណ្ឌទៅលើនីតិបុគ្គលនោះទេ។ នេះហើយគឺជាលក្ខណ្ឌចាំបាច់មួយ ដែលត្រូវតែមានចែងនៅក្នុងច្បាប់យ៉ាងជាក់លាក់តែម្តង។[103]

**២.២. ការមិនទទួលខុសត្រូវរបស់នីតិបុគ្គលសាធារណៈ**

នីតិបុគ្គលសាធារណៈ គឺជាបុគ្គលអរូបដែលច្បាប់បង្កើតមកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ និងសេវាកម្មសាធារណៈ ដោយមិនស្វែងរកប្រាក់ចំនេញ។ ប្រសិនបើនីតិបុគ្គលសាធារណៈ បានប្រព្រឹត្តនូវអំពើដែលផ្ទុយពីច្បាប់ ឬអាចនិយាយថាអំពើដែលច្បាប់មានចែងជាអំពើខុសច្បាប់ នីតិបុគ្គលនោះមិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ ទោះបីជាមានការប្រព្រឹត្តបទល្មើសដោយតំណាងរបស់នីតិបុគ្គល ហើយវាជាផលប្រយោជន៍សម្រាប់នីតិបុគ្គលនោះក៏ដោយ ក៏មានលក្ខខណ្ឌពិសេសមួយទៀត ដែលអនុញ្ញាតឲ្យនីតិបុគ្គលសាធារណៈពិសេសនេះមិនទទួលខុសត្រូវក្នុងរឿងព្រហ្មទណ្ឌដែរគឺរដ្ឋ។ រដ្ឋជានីតិបុគ្គលសាធារណៈដែលមិនទទួលខុសត្រូវក្នុងរឿងព្រហ្មទណ្ឌឡើយ។ ដូចនេះរដ្ឋជានីតិបុគ្គលពិសេសតែមួយគត់ ដែលមិនទទួលខុសត្រូវក្នុងរឿងព្រហ្មទណ្ឌ ដោយសាររដ្ឋជាអ្នកបង្កើតច្បាប់សម្រាប់ដាក់ទណ្ឌដល់បុគ្គលណា ដែលមិនប្រតិបត្តិតាម ពោលរដ្ឋមិនបង្កើតច្បាប់ដាក់ទណ្ឌកម្មខ្លួនឯងឡើយ ហើយវាជាការងារសំខាន់មួយទៀតគឺរដ្ឋមានតួនាទីដឹកនាំកិច្ចការទាំងអស់នៅក្នុងប្រទេស ដែលរដ្ឋជាអ្នកទទួលខុសត្រូវលើបញ្ហាទាំងអស់ ដើម្បីរៀបចំសង្គម និងអភិវឌ្ឍន៍ប្រទេសជាតិឲ្យរីកចម្រើនជានិរន្តរ៍។ ប៉ុន្តែចំពោះសំណងរដ្ឋប្បវេណីវិញ រដ្ឋនៅតែមានកាតព្វកិច្ចសងសំណងទៅលើរាល់ការខូចខាតទាំងឡាយណា ដែលបណ្តាលមកពីអំពើតាមរយៈតំណាងរបស់ខ្លួន ក្នុងការបំពេញការងារក្នុងនាមរដ្ឋជាដាច់ខាត។

[103] កៅ សីហា, *នីតិព្រហ្មទណ្ឌទូទៅ* (ភ្នំពេញ៖ អង្គរ, ២០១៣), ២០៥។

រដ្ឋ គឺជានីតិបុគ្គលពិសេសមួយដែលច្បាប់មិនឲ្យទទួលខុសត្រូវព្រហ្មទណ្ឌទេ ពីព្រោះថាច្បាប់ព្រហ្មទណ្ឌនៅក្នុងទោសបន្ថែម គឺអាចរំលាយនីតិបុគ្គលមួយចោលបាន។[104] ដូចនេះបើសិនជាឲ្យរំលាយនីតិបុគ្គលដែលជារដ្ឋ ឬប្រទេសមួយចោល ពេលនោះនឹងធ្វើឲ្យប៉ះពាល់អធិបតេយ្យជាតិ ដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញជាក់ជាមិនខាន។[105]

## សេចក្ដីសន្និដ្ឋាន

សរុបមកគេអាចសន្និដ្ឋានបានថា អំពើល្មើសទាំងឡាយណាដែលត្រូវបានប្រព្រឹត្តត្រឹមត្រូវតាមច្បាប់កំណត់នោះ គឺជាលក្ខខណ្ឌនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ។ យោងតាមការស្រាវជ្រាវរបស់យើងខ្ញុំ

[104] កៅ សីហា, *នីតិព្រហ្មទណ្ឌទូទៅ* (ភ្នំពេញ៖ អង្គរ, ២០១៣), ២០៤។

[105] កៅ សីហា, *នីតិព្រហ្មទណ្ឌទូទៅ* (ភ្នំពេញ៖ អង្គរ, ២០១៣), ២០៤។

លក្ខខណ្ឌនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ មាន៣មូលហេតុសំខាន់គឺ មូលហេតុអត្តនោម័ត មូលហេតុសត្យានុម័ត ឬយុត្តិកម្មនៃបទល្មើស និងមូលហេតុផ្សេងទៀត(និយាយពីនីតិភាព និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)។

នៅក្នុងមូលហេតុអត្តនោម័ត ត្រូវបានកំណត់ថា ចារីនឹងមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ប្រសិនបើចារីនោះបានប្រព្រឹត្តបទល្មើសនៅពេលដែលខ្លួនស្ថិតក្នុងភាពវិបល្លាសស្មារតី និងការប្រព្រឹត្តបទល្មើសដោយសារខ្លួនស្ថិតក្រោមអានុភាពនៃកម្លាំង ឬការបង្ខំ។ វិបល្លាសស្មារតី សំដៅលើវិបត្តិដែលធ្វើឲ្យមានភាពរឹករវដល់សកម្មភាពនៃសរសៃប្រសាទរបស់មនុស្ស។ វិបល្លាសស្មារតីអាចមានប្រភពមកពីជរាភាពគ្រោះថ្នាក់ ឬមកពីជម្ងឺណាមួយជាដើម។ ដោយសារប្រព័ន្ធសរសៃប្រសាទមានសកម្មភាពមិនប្រក្រតី ចារីបានបាត់បង់នូវលទ្ធភាពយល់ដឹងពីពិភពខាងក្រៅជុំវិញខ្លួន ហើយពុំអាចត្រួតពិនិត្យសកម្មភាពរបស់ខ្លួនបានទេ។ ជាមួយគ្នានេះ បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬនៃការបង្ខំ ដែលបុគ្គលនេះមិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ។ កម្លាំង និងការបង្ខំអាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ។ កម្លាំងនេះត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចចៀសបាន។

លើសពីនេះទៅទៀត នៅក្នុងមូលហេតុសត្យានុម័ត ឬយុត្តិកម្មនៃបទល្មើស ក៏ត្រូវបានកំណត់ថា ចារីមិនទទួលខុសត្រូវព្រហ្មទណ្ឌដែរ ប្រសិនបើចារីនោះប្រព្រឹត្តបទល្មើសដោយសារ មានមូលហេតុចំនួន៤គឺ ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ ការការពារស្របច្បាប់ សច្ចធារណ៍នៃការការពារស្របច្បាប់ និងការប្រព្រឹត្តបទល្មើសក្នុងស្ថានភាពចាំបាច់។ មូលហេតុស្តីពីអំពើយុត្តិកម្ម គឺជាមូលហេតុដែលគេចាត់ទុកថាចេញមកពីក្រៅបុគ្គលនៃចារី

ហើយដែលធ្វើឲ្យចារីបានរួចផុតពីការទទួលខុស នឹងនាំឲ្យអ្នកផ្តើមគំនិត ឬអ្នកសមគំនិតក៏រួចផុតពីការមិនទទួលខុសត្រូវព្រហ្មទណ្ឌដូចគ្នាទៅនឹងចារីផងដែរ។

ទន្ទឹមនឹងនេះ នៅក្នុងចំណុចមូលហេតុផ្សេងទៀត យើងខ្ញុំបានបកស្រាយ២ចំណុចគឺទាក់ទងនឹងនីតិភាព និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល។ បញ្ហានីតិភាពនេះ មានន័យថា គេមិនអាចឲ្យជនដែលមិនដឹងខុសត្រូវពីភាពធ្ងន់ធ្ងរនៃអំពើរបស់ខ្លួនឲ្យទទួលខុសត្រូវព្រហ្មទណ្ឌទេ។

ការយល់ដឹងខុសត្រូវជាកត្តាមួយដែលនាំឲ្យបុគ្គលម្នាក់ៗ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។ កំណត់នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺនៅត្រឹមអាយុ១៨ឆ្នាំឡើងទៅ។ រីឯការមិនទទួលខុសត្រូវព្រហ្មទណ្ឌនីតិបុគ្គល មានន័យថា ទោះបីជាច្បាប់បានកំណត់អំពីគោលការណ៍ នៃការទទួលខុសត្រូវព្រហ្មទណ្ឌក៏ដោយក៏ច្បាប់បានកំណត់អំពីគោលការណ៍អញ្ញត្រកម្មមួយចំនួន ដែលអនុញ្ញាតឲ្យនីតិបុគ្គលអាចមិនទទួលខុសត្រូវព្រហ្មទណ្ឌបានដែរ។

## មាតិកា

ទំព័រ


**សេចក្តីផ្តើម**.....១

### ជំពូកទី១
### មូលហេតុដែលហៅថាអត្តនោម័ត

**ផ្នែកទី១ មូលហេតុអត្តនោម័តដោយសារមានវិបល្លាសស្មារតី** .....៣

១.១.ជនវិបល្លាសស្មារតីទាំងស្រុងនូវការយល់ដឹង .....៣

១.២. ជនវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវ .....៤

១.៣. ជនដែកមានវិបល្លាសស្មាតីដោយសារការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន.......៦

**ផ្នែកទី២ មូលហេតុអត្តនោម័តដោយសារអានុភាពនៃកម្លាំង ឬការបង្ខំ** .....៨

២.១.ប្រភេទនៃកម្លាំង ឬការបង្ខំ.....៩

២.១.១.កម្លាំងលើរូបកាយ.....១០

២.១.២.ការបង្ខំលើផ្លូវចិត្ត.....១០

២.២.លក្ខណៈកម្លាំង ឬការបង្ខំ.....១២

២.២.១.កម្លាំងឬការបង្ខំដែលមិនអាចមើលឃើញជាមុនបាន.....១២

២.២.២.កម្លាំង ឬការបង្ខំដែលមិនអាចជៀសវាងបាន.....១៣

### ជំពូកទី២
### មូលហេតុដែលហៅថាសត្យានុម័ត ឬ យុត្តិកម្មនៃបទល្មើស

**ផ្នែកទី១ ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ** .....១៤

១.១.ការអនុញ្ញាតដោយច្បាប់.....១៦

១.២.ការបញ្ជាដោយអាជ្ញាធរស្របច្បាប់ .....១៧

១.២.១.អាជ្ញាធរស្របច្បាប់.....១៧

១.២.២. បញ្ជាស្របច្បាប់.....១៨

**ផ្នែកទី២ ការការពារស្របច្បាប់**.....១៩

**ផ្នែកទី៣ សច្ចធារណ៍ការការពារស្របច្បាប់** .....២១

**ផ្នែកទី៤ ស្ថានភាពចាំបាច់**.....២២

៤.១.គ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន.....២៤

៤.២.គ្មានវិសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់.....២៥

## ជំពូកទី៣

## មូលហេតុផ្សេងទៀត

**ផ្នែកទី១ មូលហេតុទាក់ទងនឹងនីតិភាព** ........................................................................ ២៧

១.១.វិធានការអនុវត្តចំពោះអនីតិជន ........................................................................ ២៨

១.២.ទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជន ........................................................................ ២៩

**ផ្នែកទី២ មូលហេតុទាក់ទងនីតិបុគ្គល** ........................................................................ ៣១

២.១.ការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលឯកជន ........................................ ៣១

២.២.ការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលសាធារណៈ ........................ ៣៣

**សេចក្តីសន្និដ្ឋាន** ........................................................................................ ៣៥

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

## ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

១. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

២. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

៣. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

៤. ក្រមព្រហ្មទណ្ឌចាស់នៃព្រះរាជាណាចក្រកម្ពុជា១៩៦៨

## សន្ធានុក្រម

១.សន្ធានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌ ចេញផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១

## ប្រភេទសៀវភៅ

១. នីតិព្រហ្មទណ្ឌទូទៅ, រុន ពណ្ណារិទ្ធ ឆ្នាំ២០១២ កែសម្រួលដោយ ចាំង ស៊ីណាត

២. នីតិព្រហ្មទណ្ឌទូទៅ, ជួន ប៊ុនធី

៣. នីតិព្រហ្មទណ្ឌទូទៅ, កៅ សីហា

៤. សេចក្តីផ្តើមនីតិនៃកម្ពុជា ឆ្នាំ២០១០

៥. សារណាបញ្ចប់ការសិក្សារបស់ លោក សុធា រស្មី និង លោក អៀង វណ្ណៈ (ឆ្នាំ២០១៦)។

# ឧបសម្ព័ន្ធ

# ក្រម

# ព្រហ្មទណ្ឌ

# ព្រះរាជក្រម

នស/រកម/១១០៩/០២២

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពូរហាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ស្ថាប័នតុលាការដែលត្រូវបានតែងតាំងដោយលិខិតបទដ្ឋានគតិយុត្ត ទោះជាអចិន្ត្រៃយ៍ ឬ ជាបណ្តោះអាសន្នក្តី ទោះជាបានទទួល ឬ មិនបានប្រាក់ឈ្នួលក្តី ដោយមិនគិតពីឋានៈ អាយុ របស់បុគ្គលនោះឡើយ ។

ខ/ បុគ្គលឯទៀត ដែលធ្វើការក្នុងមុខងារសាធារណៈ រួមទាំងទីភ្នាក់ងារសាធា-រណៈ ឬសហគ្រាសសាធារណៈ ព្រមទាំងស្ថាប័នសាធារណៈដទៃទៀត ដែលមានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

២- ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត មានន័យថាជាសមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដើម្បីបំពេញមុខងារសាធារណៈដទៃទៀត ។

## ជំពូកទី ២

## មូលហេតុនៃការមិនទទួលខុសត្រូវ ឬ ការសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌ

**មាត្រា ៣១.-** ការមិនទទួលខុសត្រូវដោយសារមូលហេតុវិបល្លាសស្មារតី

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតីដែលធ្វើឱ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ។ ប៉ុន្តែ តុលាការត្រូវគិតគូរអំពីបញ្ហានេះ កាលណាតុលាការកំណត់ទោស ។

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតីដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬ សារធាតុដែលច្បាប់ហាមឃាត់ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។

**មាត្រា ៣២.-** ការអនុញ្ញាតដោយច្បាប់ ឬ អាជ្ញាធរ

បុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្ត ឬ អនុញ្ញាតតាមច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់ ។

ប៉ុន្តែ ចារី សហចារី អ្នកផ្តើមគំនិត ឬ អ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬ បទឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបីជាក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ :

១-ជនល្មើសនោះបានប្រព្រឹត្តអំពើដែលបញ្ញត្ត អនុញ្ញាត ឬ មិនហាមឃាត់ដោយច្បាប់ជាធរមាន ។

២-បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ ។

**មាត្រា ៣៣.–** ការការពារស្របច្បាប់

បុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការពារស្របច្បាប់ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ការការពារស្របច្បាប់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការល្មោភពានមួយដែលមិនត្រឹមត្រូវ

-បទល្មើស និងការល្មោភពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និង

-គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការល្មោភពាន ។

**មាត្រា ៣៤.–** សច្ចធារណ៍នៃការការពារស្របច្បាប់

ត្រូវសន្មតថាជាការការពារស្របច្បាប់ នៅក្នុងករណីដូចតទៅ :

១-បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬ ដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ ។

២-បទល្មើសបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬ ការប្លន់ដែលអនុវត្តដោយហិង្សា ។

សច្ចធារណ៍នៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ ។ សច្ចធារណ៍ នេះអាចរំលាយដោយភស្តុតាងផ្ទុយ ។

**មាត្រា ៣៥.–** ស្ថានភាពចាំបាច់

បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវបានចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬ ដែលនឹងកើតមាន និង

-គ្មានវិសមាមាត្ររវាងមធ្យោបាយការពារនិងទម្ងន់នៃគ្រោះថ្នាក់ ។

**មាត្រា ៣៦.–** អានុភាពនៃកម្លាំង ឬ ការបង្ខំ

បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬ ការបង្ខំ ដែលបុគ្គលនេះមិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ ។ កម្លាំង និងការបង្ខំនេះត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន ។

**មាត្រា ៣៧.–** ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ មិនត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌណាមួយទេ ។

## ជំពូកទី ៣

## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

**មាត្រា ៣៨.–** នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។

**មាត្រា ៣៩.–** វិធានការអនុវត្តចំពោះអនីតិជន

អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ។

ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈ របស់អនីតិជនតម្រូវ ។

**មាត្រា ៤០.-** ប្រភេទនៃវិធានការ

វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភមាន ដូចតទៅ :

១-ការប្រគល់អនីតិជនឱ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬ បុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត ។

២-ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន ។

៣-ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន ។

៤-ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស ។

៥-ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ ។

**មាត្រា ៤១.-** ការដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ

ក្នុងករណីដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការនោះ តុលាការចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន ។ បុគ្គលនេះធ្វើរបាយការណ៍ស្តីពីកិរិយាមារយាទរបស់អនីតិជនឱ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនេះផ្តល់ព័ត៌មានដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ ដែលអាចនាំឱ្យមានការកែប្រែវិធានការនេះ ។

## ជំពូកទី ៤

## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

**មាត្រា ៤២.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិ-បុគ្គល លើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទ-

ល្មើស ដែលប្រព្រឹត្តដោយអង្គការ ឬ អ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍ របស់នីតិ-បុគ្គលនោះ ។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល ក្នុងអំពើដដែលនោះទេ ។

## មាតិកាទី ៣

## ទោស

### ជំពូកទី ១

### ប្រភេទនៃទោស

#### ផ្នែកទី ១

#### មូលទោស

**មាត្រា ៤៣.-** មូលទោស

មូលទោសរួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យ ។

ការពិន័យត្រូវគិតជាប្រាក់រៀល ។

**មាត្រា ៤៤.-** អប្បបរមា និងអតិបរមានៃមូលទោស

កាលបើបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ច្បាប់កំណត់អំពីអប្បបរមា និងអតិ-បរមានៃទោសដាក់ពន្ធនាគារ ។

កាលបើបទល្មើសត្រូវផ្តន្ទាទោសពិន័យ ច្បាប់កំណត់អំពីអប្បបរមា និងអតិបរមានៃចំនួនទឹកប្រាក់ពិន័យដែលត្រូវទទួល ។

**មាត្រា ៤៥.-** ការទម្ងន់ទោស និងការសម្រាលទោស

អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ និងការពិន័យជាប្រាក់ អាចបន្ថែម ឬ បន្ថយនៅក្នុងលក្ខខណ្ឌដែលចែងដោយក្រមនេះ ។

**មាត្រា ៤៦.-** និយមន័យនៃបទឧក្រិដ្ឋ

បទល្មើសជាបទឧក្រិដ្ឋ នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

15/26k

១-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

២-ការបិទគ្រឹះស្ថាន ។

៣-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន ។

## ជំពូកទី ៦

## ទោសដែលអាចអនុវត្តចំពោះអនីតិជន

### ផ្នែកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១៦០.-** មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ

កាលណាតុលាការ សម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ :

១-អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ។

២-ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ ។

៣-អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ ។

៤-អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមចិរវេលាស្មើ ឬ តិចជាង ៥ (ប្រាំ)ឆ្នាំ នោះ បទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល ។

**មាត្រា ១៦១.-** ទោសបន្ថែម

មានតែទោសបន្ថែមដូចតទៅនេះប៉ុណ្ណោះ ដែលអាចអនុវត្តទៅលើអនីតិជន :

១-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

## គន្ថីទី ២

## បទល្មើសប្រឆាំងនឹងបុគ្គល

## មាតិកាទី ១

## បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋសង្គ្រាម

## ជំពូកទី ១

## បទឧក្រិដ្ឋប្រល័យពូជសាសន៍

**មាត្រា ១៨៣.-** បទឧក្រិដ្ឋប្រល័យពូជសាសន៍

បទឧក្រិដ្ឋប្រល័យពូជសាសន៍ គឺជាអំពើណាមួយក្នុងចំណោមអំពើដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនេះត្រូវបានប្រព្រឹត្តក្នុងគោលបំណងបំផ្លាញទាំងមូល ឬ មួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា :

១-ឃាតកម្មលើសមាជិកនៃក្រុម ។

២-ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើបូរណភាពខាងរូបកាយ ឬ សតិបញ្ញារបស់សមាជិកនៃក្រុម ។

៣-ការដាក់ឱ្យសមាជិកនៃក្រុមរស់នៅក្នុងលក្ខខណ្ឌ ដែលនាំឱ្យវិនាសអន្តរាយទាំងស្រុង ឬ មួយផ្នែកនៃក្រុម ។

៤-វិធានការដោយបង្ខំ ឬ មធ្យោបាយដោយមិនបង្ខំ សំដៅរារាំងកំណើតទារកនៅក្នុងក្រុម ។

៥-ជម្លៀសដោយបង្ខំនូវកុមារពីក្រុមមួយទៅក្រុមមួយផ្សេងទៀត ។

**មាត្រា ១៨៤.-** ទោសដែលត្រូវទទួល

បទឧក្រិដ្ឋប្រល័យពូជសាសន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ១៨៥.-** បទត្រៀមរៀបចំក្នុងបទឧក្រិដ្ឋប្រល័យពូជសាសន៍

ការចូលរួមក្នុងក្រុមណាមួយដែលបង្កើតឡើង ឬចូលរួមក្នុងសន្ធិធិភាពដែលធ្វើឡើងដើម្បីរៀបចំអំពើឧក្រិដ្ឋប្រល័យពូជសាសន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

...ត្រៀមរៀបចំត្រូវមានលក្ខណៈសំគាល់ដោយអំពើជាក់ស្តែងមួយ ឬ ច្រើន ។

## ជំពូកទី ២
## បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ

**មាត្រា ១៨៨.–** បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ

បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ គឺជាអំពើណាមួយក្នុងចំណោមអំពើដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនេះត្រូវបានប្រព្រឹត្តទៅក្នុងក្របខ័ណ្ឌនៃការវាយលុកជាទូទៅ ឬ ជាប្រព័ន្ធ សំដៅប្រឆាំងប្រជាជនស៊ីវិល ៖

១-ឃាតកម្ម ។

២-ការសម្លាប់រង្គាល ។

៣-ការធ្វើឱ្យទៅជាទាសករ ។

៤-ការនិរទេស ឬ ជម្លៀសប្រជាជនដោយបង្ខំ ។

៥-ការដាក់ពន្ធនាគារ ឬ គ្រប់រូបភាពដទៃទៀតនៃការដកហូតយ៉ាងធ្ងន់ធ្ងរនូវសេរីភាពដោយបំពានទៅលើបទប្បញ្ញត្តិគ្រឹះនៃនីតិអន្តរជាតិ ។

៦-ការធ្វើទារុណកម្ម ។

៧-ការចាប់បង្ខំសេពសន្ថវៈ ការធ្វើទាសកម្មខាងផ្លូវភេទ ពេស្យាចារដោយបង្ខំ ការមានគភ៌ដោយបង្ខំ វណ្ណកម្មដោយបង្ខំ និងគ្រប់រូបភាពផ្សេងទៀតនៃអំពើហិង្សាខាងផ្លូវភេទ ដែលមានទម្ងន់ប្រហាក់ប្រហែលគ្នា ។

៨-ការធ្វើទុក្ខបុកម្នេញលើក្រុម ឬ សមូហភាពដោយមូលហេតុនយោបាយ ពូជសាសន៍ ក្រុមជាតិ ជាតិពន្ធុ វប្បធម៌ សាសនា ឬ ភេទ ។

៩-ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ។

១០-ការអនុវត្តនយោបាយប្រកាន់ពូជសាសន៍ជាប្រព័ន្ធតាមបែបអាផាថេដ ។

១១-គ្រប់អំពើអមនុស្សធម៌ផ្សេងទៀត ដែលបង្កឱ្យមានការឈឺចាប់យ៉ាងខ្លាំង ឬ ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើបូរណភាពខាងរូបកាយ ។

**មាត្រា ១៨៩.–** ទោសដែលត្រូវទទួល

បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ១៩០.–** បទត្រៀមរៀបចំក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ

ការចូលរួមក្នុងក្រុមដែលបង្កើតឡើង ឬ សន្ធិដ្ឋិភាពដែលធ្វើឡើងដើម្បីរៀបចំអំពើ

## ជំពូកទី ៣

## បទឧក្រិដ្ឋសង្គ្រាម

**មាត្រា ១៩៣.-** បទឧក្រិដ្ឋសង្គ្រាម

បទឧក្រិដ្ឋសង្គ្រាម គឺជាអំពើណាមួយក្នុងចំណោមអំពើដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនោះត្រូវបានប្រព្រឹត្តប្រឆាំងនឹងបុគ្គល ឬ ទ្រព្យសម្បត្តិ ដែលការពារដោយអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ :

១-ឃាតកម្ម ។

២-ទារុណកម្ម ឬ គ្រប់អំពើអមនុស្សធម៌ រួមបញ្ចូលទាំងការពិសោធជីវសាស្ត្រ ។

៣-អំពើបង្កដោយចេតនានូវការឈឺចាប់ ឬ ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បូរណភាពខាងរូបកាយ ឬ សុខភាព ។

៤-ការបំផ្លាញ ឬ ការធ្វើឱ្យខូចខាតធ្ងន់ធ្ងរទៅលើទ្រព្យសម្បត្តិ ដោយគ្មានហេតុផលចាំបាច់ខាងយោធា និងក្នុងទ្រង់ទ្រាយធំដោយខុសច្បាប់ និងតាមទំនើងចិត្ត ។

៥-អំពើបង្ខំឈ្លើយសឹក ឬ ជនស៊ីវិល ឱ្យបម្រើក្នុងកងកម្លាំងប្រដាប់អាវុធរបស់សត្រូវ ។

៦-អំពើដកហូតសិទ្ធិរបស់ឈ្លើយសឹក ឬ ជនស៊ីវិល ក្នុងការទទួលការវិនិច្ឆ័យដោយត្រឹមត្រូវ និងឥតលំអៀង ។

៧-ជម្លៀស ការបញ្ជូន ឬ ការឃុំឃាំងជនស៊ីវិលដោយខុសច្បាប់ ។

៨-ការចាប់ជនស៊ីវិលជាចំណាប់ខ្មាំង ។

**មាត្រា ១៩៤.-** បទឧក្រិដ្ឋសង្គ្រាមផ្សេងទៀត

អំពើណាមួយដូចមានចែងខាងក្រោមនេះ គឺជាបទឧក្រិដ្ឋសង្គ្រាមដែរ កាលបើអំពើនោះ ត្រូវបានប្រព្រឹត្តក្នុងនិកាសជម្លោះប្រដាប់អាវុធជាលក្ខណៈអន្តរជាតិ ឬ មិនមែនអន្តរ-ជាតិ :

១-ការប្រើប្រាស់អាវុធដែលមានជាតិពុល ឬ អាវុធដែលស្ថាបនាឡើងដើម្បីបង្កការឈឺចាប់ឥតប្រយោជន៍ ។

២-អំពើវាយប្រហារ ឬ ទម្លាក់គ្រាប់បែកដោយចេតនា តាមមធ្យោបាយណាក៏... ទៅលើទីក្រុង ភូមិ ទីកន្លែងរស់នៅ ឬ អគារដែលមិនមានការការពារ និងដែលមិន

# ក្រមនីតិវិធីព្រហ្មទណ្ឌ

# ព្រះរាជក្រម

នស/រកម/០៨០៧/០២៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

34/2404

## គន្ថីទី ៣
## ការស៊ើបអង្កេត
## មាតិកាទី ១
## បទប្បញ្ញត្តិទូទៅ
## ជំពូកគោល
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៨៣.** – ការសម្ងាត់នៃការស៊ើបអង្កេត

ការស៊ើបអង្កេត ត្រូវតែជាការសម្ងាត់ ។ បុគ្គលទាំងឡាយ ដែលចូលរួមក្នុងការស៊ើបអង្កេត ជាពិសេសចៅក្រមខាងអយ្យការ មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ) នៃក្រមនេះ ត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈ ។

ប៉ុន្តែ ការគោរពនូវការសម្ងាត់វិជ្ជាជីវៈ មិនមែនជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនឡើយ ។

ម្យ៉ាងទៀត ព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ កាលណាខ្លួនយល់ឃើញថាព័ត៌មានដែលផ្សព្វផ្សាយពីរឿងណាមួយនោះ ជាព័ត៌មានមិនពិត ។

ការបំពានលើការសម្ងាត់នៃការស៊ើបអង្កេត គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៨៤.** – ភាពខុសគ្នានៃអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ទៅតាមការស៊ើបអង្កេត

អំណាចទាំងឡាយ ដែលផ្តល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ខុសគ្នាទៅតាមពេលដែលមន្ត្រីនោះបំពេញការក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែង ឬក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋម ។

## មាតិកាទី ២
## ការស៊ើបអង្កេតករណីជាក់ស្តែង
## ជំពូកទី ១
## បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

**មាត្រា ៨៥.** – អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្តែង

ក្នុងករណីមានបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែគោរពតាម

បទបញ្ញត្តិនៃមាត្រានេះ ។

**មាត្រា ៨៦.** – និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែង

បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែងគឺ :

-បទល្មើសដែលកំពុងប្រព្រឹត្ត

-បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម ។

ត្រូវចាត់ទុកថា ជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក :

-ជនដែលគេសង្ស័យ ត្រូវបានសាធារណជនស្រែកដេញប្រដាប់ចាប់ប្រភឹង

-បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស ។

**មាត្រា ៨៧.** – ការចាប់ខ្លួនក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែង

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែង គ្រប់បុគ្គលទាំងអស់អាចចាប់ខ្លួនជនល្មើស ហើយនាំខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត ។

**មាត្រា ៨៨.** – ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែង

ត្រូវបានចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែងផងដែរ បើទោះបីជាស្ថិតនៅក្រៅពីករណីដែលមានចែងក្នុងមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែង) ខាងលើនេះក៏ដោយ គ្រប់បទឧក្រិដ្ឋ ឬបទមជ្ឈិមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះ សុំឱ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ ។ ក្នុងករណីចុងក្រោយនេះ ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌ ។

## ជំពូកទី ២
## វិធានការស្រាវជ្រាវ

**មាត្រា ៨៩.** – វិធានការដំបូងក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែង

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ។

មុននឹងចុះហត្ថលេខា ឬផ្តិតស្រាមមេដៃ បុគ្គលនោះត្រូវអានកំណត់ហេតុឡើងវិញ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានដោយសំលេងខ្លាំងៗ នូវខ្លឹមសារកំណត់ហេតុ ។ មន្ត្រីនគរបាលយុត្តិធម៌ អាចហៅអ្នកបកប្រែបាន ។ កាលណាបុគ្គលនោះមិនព្រមចុះហត្ថលេខា ឬមិនព្រមផ្តិតស្រាមមេដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។

**មាត្រា ៩៤.** – បទបញ្ជាឱ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបាន ។

បុគ្គលដែលកោះហៅនោះ ត្រូវចូលបង្ហាញខ្លួន ។ ក្នុងករណីរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា ដែលអាចចេញបញ្ជាឱ្យចូលខ្លួនបាន ។ បញ្ជាឱ្យចូលខ្លួននេះ ត្រូវមានអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ មានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផង ។ បញ្ជាឱ្យចូលខ្លួន អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះ ឱ្យចូលបង្ហាញខ្លួន ។ កថាខណ្ឌទី ២ ដល់ទី ៥ នៃមាត្រា ៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ) នៃក្រមនេះ ត្រូវយកមកអនុវត្ត ។

**មាត្រា ៩៥.** – ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ

ប្រសិនបើត្រូវធ្វើការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បាន មន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលគ្រប់រូបដែលមានមុខជំនាញ ។ ប្រសិនបើបុគ្គលនោះមិនទាន់បានចុះឈ្មោះនៅក្នុងបញ្ជីអ្នកជំនាញដូចចែងនៅមាត្រា ១៦៣ (បញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ) នៃក្រមនេះទេ បុគ្គលនេះត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា នឹងជួយដោយភក្តីភាពដល់តុលាការ ។

## ជំពូកទី ៣
## ការឃាត់ខ្លួន

**មាត្រា ៩៦.** – ការឃាត់ខ្លួន

ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ អាចឃាត់ខ្លួនបុគ្គលដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបានដែរ ប្រសិនបើលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :

-បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន

-មានការយល់ព្រមជាលាយលក្ខណ៍អក្សរឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា ។

## មាតិកាទី ៣
## ការស៊ើបអង្កេតបឋម
## ជំពូកទោល
## ការស៊ើបអង្កេតបឋម

**មាត្រា ១១១.** – ការបើកការស៊ើបអង្កេតបឋម

កាលណាបានដឹងពីអំពើដែលអាចជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬតាមការសុំរបស់ព្រះរាជអាជ្ញា ។

**មាត្រា ១១២.** – វិធានដែលអនុវត្តចំពោះការស៊ើបអង្កេតបឋម

បទប្បញ្ញត្តិនៃមាត្រា :

-មាត្រា ៩០ (កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ)

-មាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ)

-មាត្រា ១០៥ (ការហាមឃាត់មិនឱ្យស្ដាប់ដោយឯកឯង ជាអាទិ៍)

-មាត្រា ១០៧ (ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា)

-មាត្រា ១០៨ (និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ) នៃក្រមនេះ

ត្រូវយកមកអនុវត្តនៅក្នុងការស៊ើបអង្កេតបឋម ។

**មាត្រា ១១៣.** – ការឆែកឆេរ

កាលណាការស៊ើបអង្កេតជាបឋមនោះ ទាក់ទងនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង ។

មន្ត្រីនគរបាលយុត្តិធម៌ ជាបឋមត្រូវទទួលការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង ។

ការយល់ព្រមនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ សរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង ។ ប្រសិនបើអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរ នោះត្រូវសរសេរឱ្យបានច្បាស់លាស់ក្នុងកំណត់ហេតុថា អ្នកកាន់កាប់ទីកន្លែងនោះមិនចេះអក្សរ ហើយយល់ព្រមឱ្យឆែកឆេរ ។

ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធការឆែកឆេរ ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដី អាចចេញដីកាអនុញ្ញាតឱ្យឆែកឆេរ តាមការសុំរបស់ព្រះរាជអាជ្ញា ។ ព្រះរាជអាជ្ញា ត្រូវដឹកនាំដោយផ្ទាល់នូវការឆែកឆេរនេះ ។ ការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់។ សាក្សីត្រូវចាត់

តាំងដោយព្រះរាជអាជ្ញា ។ សាក្សីមិនអាចជានគរបាល ឬជាកងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះឡើយ ។ ការឆែកឆេរមិនអាចផ្ដើមមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយ ម៉ោង ១៨ (ដប់ប្រាំបី) ឡើយ ។

បទប្បញ្ញត្តិនៃមាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង) នៃក្រមនេះ ត្រូវយកមកអនុវត្តក្នុងការចាប់យកវត្ថុតាង ។

**មាត្រា ១១៤.** – ការបញ្ជាឱ្យចូលខ្លួន ការស៊ើបអង្កេតបឋម

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្ដាប់ចម្លើយបុគ្គលគ្រប់រូបដែលត្រូវបានសង្ស័យថា បានចូលរួមក្នុងបទល្មើស ឬដែលអាចផ្ដល់ព័ត៌មានស្ដីពីរឿងហេតុ ។

បុគ្គលដែលកោះហៅត្រូវតែចូលមកបង្ហាញខ្លួន ។ ក្នុងករណីរឹងទទឹងមន្ត្រីនគរបាលយុត្តិធម៌ជូនដំណឹងដល់ព្រះរាជអាជ្ញាដែលអាចចេញបញ្ជាឱ្យចូលខ្លួន ។ បញ្ជាឱ្យចូលខ្លួននេះត្រូវមានចុះអត្តសញ្ញាណបុគ្គលពាក់ព័ន្ធ កាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រា ។

បញ្ជាឱ្យចូលខ្លួន អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កងកម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឱ្យចូលបង្ហាញខ្លួន ។

**មាត្រា ១១៥.** – កំណត់ហេតុស្រង់ចម្លើយ ការស៊ើបអង្កេតបឋម

ការស្ដាប់ចម្លើយនីមួយៗ ត្រូវមានធ្វើកំណត់ហេតុ ។

កំណត់ហេតុត្រូវដកស្រង់ដោយត្រឹមត្រូវតាមចម្លើយរបស់បុគ្គលពាក់ព័ន្ធ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌អាចហៅអ្នកបកប្រែដែលបានស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថា ខ្លួននឹងបកប្រែឱ្យបានត្រឹមត្រូវ ។ អ្នកបកប្រែមិនអាចត្រូវ បានជ្រើសរើសក្នុងចំណោមនគរបាល កងរាជអាវុធហត្ថ ឬបុគ្គលដែលពាក់ព័ន្ធនៅក្នុងរឿងជាមួយទេ ។

**មាត្រា ១១៦.** – ការឃាត់ខ្លួនជនជាប់សង្ស័យ

កាលណាការស៊ើបអង្កេតបឋមទាក់ទងនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ បទប្បញ្ញត្តិនៃជំពូកទី ៣ ស្ដីពីការឃាត់ខ្លួន និងជំពូកទី ៤ ស្ដីពីការបញ្ជូនខ្លួន នៃមាតិកាទី២ ស្ដីពីការស៊ើបអង្កេតករណីជាក់ស្ដែងក្នុងគន្ថីនេះ ត្រូវយកមកអនុវត្ត ។

**មាត្រា ១១៧.** – មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ

ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋម វិធាន និងទម្រង់ការដែលចែងនៅក្នុងមាត្រា :

-មាត្រា ៩៦ (ការឃាត់ខ្លួន)

# ក្រមរដ្ឋប្បវេណី

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ២៧.–** ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ

បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២៤ (ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ បានរលាយ តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

## កថាភាគទី ៣

## ជននៅក្រោមហិតូបត្ថម្ភ

**មាត្រា ២៨.–** ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ

១-ចំពោះជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការចាប់ផ្តើមហិតូបត្ថម្ភលើជននោះបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

២-ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសាមីខ្លួនជាជននៅក្រោមអាណាព្យាបាលទូទៅ តុលាការត្រូវលុបចោលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅចំពោះជននោះ ។

**មាត្រា ២៩.–** អត្ថន័យនៃជននៅក្រោមហិតូបត្ថម្ភ និង ការជ្រើសតាំងហិតូបត្ថម្ភកៈ

ជនដែលបានទទួលការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ ត្រូវហៅថា ជននៅក្រោមហិតូបត្ថម្ភ ហើយត្រូវស្ថិតនៅក្រោមការថែរក្សាដោយហិតូបត្ថម្ភកៈ ។

**មាត្រា ៣០.–** សិទ្ធិលុបចោលសកម្មភាព

លើកលែងតែសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ សកម្មភាពដែល

ជាមួយអ្នកផ្សេងហើយ អាពាហ៍ពិពាហ៍មុនត្រូវរលាយ ដោយសារអាពាហ៍ពិពាហ៍ក្រោយនោះ ។

## ផ្នែកទី ៧
## ការចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា

**មាត្រា ៤៥.–** ការចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា

ក្នុងចំណោមបុគ្គលដែលបានទទួលមរណភាពជាច្រើននាក់ ប្រសិនបើមិនច្បាស់លាស់ថា មានបុគ្គលណាម្នាក់នៅរស់ ក្រោយពេលបុគ្គលផ្សេងទៀតបានទទួលមរណភាពទេ បុគ្គលទាំងនោះត្រូវបានចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា ។

# ជំពូកទី ២
# នីតិបុគ្គល
## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

### កថាភាគទី ១
### និយមន័យ ប្រភេទ និង គោលការណ៍នៃការបង្កើត

**មាត្រា ៤៦.–** និយមន័យ ប្រភេទ និង គោលការណ៍នៃការបង្កើតនីតិបុគ្គល

១-នៅក្នុងក្រមនេះ ក្រុមដែលមានសមាជិក ហើយត្រូវបានប្រគល់នូវឋានៈជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ចដោយឯករាជ្យ ហៅថា នីតិបុគ្គលសាជីវកម្ម ចំណែកឯទ្រព្យសម្បត្តិវិភាគទានដែលត្រូវបានប្រគល់នូវឋានៈជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ចដោយឯករាជ្យ ហៅថា នីតិបុគ្គលមូលនិធិ ។

២-នៅក្នុងក្រមនេះ នីតិបុគ្គលដែលគ្មានគោលបំណងទាញយកចំណេញ ហៅថា នីតិបុគ្គលមិនយកចំណេញ ចំណែកឯនីតិបុគ្គលដែលទាញយកចំណេញ ហៅថា នីតិបុគ្គល

យកចំណេញ ។ នៅក្នុងចំណោមនីតិបុគ្គលមិនយកចំណេញ នីតិបុគ្គលដែលមានគោលបំណងពិសេសដើម្បីបម្រើប្រយោជន៍សាធារណៈ ហៅថា នីតិបុគ្គលបម្រើប្រយោជន៍សាធារណៈ ។

៣-នៅក្នុងក្រមនេះ នីតិបុគ្គលសាជីវកម្មដែលសមាជិកទទួលខុសត្រូវនូវកាតព្វកិច្ចរបស់នីតិបុគ្គល តាមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានធ្វើវិភាគទាន ហៅថា នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ចំណែកឯនីតិបុគ្គលសាជីវកម្មដែលសមាជិកទទួលខុសត្រូវនូវកាតព្វកិច្ចរបស់នីតិបុគ្គល ដោយយកទ្រព្យសម្បត្តិទូទៅរបស់ខ្លួន ហៅថា នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។

៤-នីតិបុគ្គលមិនអាចធ្វើជាសមាជិកដែលទទួលខុសត្រូវគ្មានកម្រិតរបស់នីតិបុគ្គលសាជីវកម្មផ្សេងទៀតបានឡើយ ។

៥-នីតិបុគ្គលមិនយកចំណេញ អាចបង្កើតឡើងតាមក្រមនេះ ឬ បទដ្ឋានគតិយុត្តផ្សេងទៀតបាន ។

៦-នីតិបុគ្គលទាញយកចំណេញ អាចបង្កើតឡើងបាន ដោយយោងទៅតាមបញ្ញត្តិនៃច្បាប់ផ្សេង ។

## កថាភាគទី ២
## នាមករណ៍នៃនីតិបុគ្គលមិនយកចំណេញ

**មាត្រា ៤៧.–** នាមករណ៍នៃនីតិបុគ្គលមិនយកចំណេញ

១-អង្គភាពដែលមិនមែនជានីតិបុគ្គលសាជីវកម្ម ឬ មិនមែនជានីតិបុគ្គលមូលនិធិ មិនអាចប្រើពាក្យ “នីតិបុគ្គលសាជីវកម្ម” ឬ “នីតិបុគ្គលមូលនិធិ” ក្នុងនាមករណ៍របស់ខ្លួនបានឡើយ ។

២-ចំពោះនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ត្រូវបង្ហាញថា ជានីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត នៅក្នុងនាមករណ៍នោះ ចំណែកឯនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ត្រូវបង្ហាញថា ជានីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត

**មាត្រា ៧៥៤.-** អំពើអនីត្យានុកូលរួម

១-បើការខូចខាតបានកើតឡើង ដោយសារអំពើរបស់បុគ្គលច្រើននាក់រួមគ្នា អ្នកប្រព្រឹត្តអំពើបំពាននីមួយៗត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គីភាព ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើអ្នកប្រព្រឹត្តអំពើបំពាននីមួយៗបានបញ្ជាក់អំពីភាគនៃអំពើដែលខ្លួនបានបង្កឱ្យមានការខូចខាត ជននោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត តាមសមាមាត្រនៃភាគដែលខ្លួនបានបង្ក ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលទទួលស្គាល់ថាមានការសមគំនិត ឬ មានទំនាក់ទំនងសហការយ៉ាងជិតស្និទ្ធក្នុងចំណោមអ្នកប្រព្រឹត្តអំពើបំពាន ។

៣-បើជនម្នាក់ក្នុងចំណោមអ្នកប្រព្រឹត្តអំពើអនីត្យានុកូលរួម បានសងការខូចខាតទាំងអស់ ដោយចេញចំណាយរបស់ខ្លួន ជននោះអាចទាមទារសំណងពីអ្នកផ្សេងទៀតដែលប្រព្រឹត្តអំពើអនីត្យានុកូលរួមនោះបាន តាមសមាមាត្រនៃភាគដែលជនម្នាក់ៗបានបង្ក ។

**មាត្រា ៧៥៥.-** និយមន័យនៃការការពារជាធម្មានុរូប និង ស្ថានភាពចាំបាច់

១-អំពើការពារជាធម្មានុរូប សំដៅទៅលើអំពើវិលោភដែលពុំអាចជៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃ ចំពោះអំពើបំពានមិនត្រឹមត្រូវ ហើយដែលស្ថិតក្នុងករណីដែលពេលវេលានៃអំពើបំពាន និង អំពើវិលោភនោះ ស្ថិតជិតគ្នា និង មានតុល្យភាពរវាងវិធីការពារនិងកម្រិតនៃអំពើបំពាននោះ ។

២-អំពើដោយសារស្ថានភាពចាំបាច់ សំដៅទៅលើអំពើវិលោភដែលពុំអាចជៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃ ចំពោះគ្រោះថ្នាក់បច្ចុប្បន្ន ឬ អច្ចាសន្ន ហើយដែលស្ថិតក្នុងករណីមានតុល្យភាព រវាងវិធីការពារ និង កម្រិតគ្រោះថ្នាក់នោះ ។

**មាត្រា ៧៥៦.-** មូលហេតុនៃការរួចផុតពីភាពផ្ទុយច្បាប់

១-អ្នកប្រព្រឹត្តអំពើបំពានត្រូវរួចផុតពីការទទួលខុសត្រូវ ក្នុងករណីដែលមានការ